ជំពូកទី ១០

# ជំនួយបឋម

## គ្រុនក្តៅ

នៅពេលរាងកាយរបស់មនុស្សម្នាក់មានសីតុណ្ហភាពក្តៅខ្លាំង គេនិយាយថាគាត់មានគ្រុនក្តៅ។ គ្រុនក្តៅមិនមែនជាជំងឺទេ ប៉ុន្តែវាអាចជារោគសញ្ញានៃជំងឺផ្សេងៗជាច្រើន។ **ទោះជាយ៉ាងណាក៏ដោយ គ្រុនក្តៅខ្លាំងអាចបណ្តាលឲ្យមានគ្រោះថ្នាក់បាន ពិសេសចំពោះកុមារតូចៗ។**

**នៅពេលមនុស្សម្នាក់មានគ្រុនក្តៅ**

១. កុំដណ្តប់អ្វីឲ្យគាត់។

ចំពោះកុមារតូចៗ គួរដោះសំលៀកបំពាក់ចេញ ហើយទុកខ្លួនឲ្យនៅទទេ រហូតដល់គ្រុនក្តៅថយចុះទៅវិញ។



*ការធ្វើរបៀបនេះ ជួយឲ្យគ្រុនក្តៅថយចុះ*




*ការធ្វើរបៀបនេះ បណ្តាលឲ្យគ្រុនក្តៅកើនឡើង*

**មិនត្រូវដណ្តប់កុមារដោយសំលៀកបំពាក់ឬភួយទេ។**

**ការដណ្តប់កុមារនៅពេលមានគ្រុនក្តៅ នាំឲ្យមានគ្រោះថ្នាក់។**

ខ្យល់បរិសុទ្ធ ឬខ្យល់ត្រជាក់ នឹងមិនធ្វើឲ្យមានគ្រោះថ្នាក់ដល់អ្នកដែលមានគ្រុនក្តៅទេ។ ផ្ទុយទៅវិញ ខ្យល់ត្រជាក់បរិសុទ្ធអាចជួយឲ្យគ្រុនក្តៅចុះថយ។

២. ការលេបថ្នាំអាស្ពីរីនក៏អាចបន្ថយគ្រុនក្តៅដែរ។ ចំពោះកុមារតូចៗ វានឹងមានសុវត្ថិភាពជាង បើគេអាចឲ្យលេបថ្នាំអាសេតាមីណូហ្វែន(Acetaminophen) (ប៉ារ៉ាសេតាមុល ទំ.៣៨០)។ ប៉ុន្តែសូមប្រយ័ត្ន កុំឲ្យច្រើនពេក។

៣. អ្នកណាដែលមានគ្រុនក្តៅគួរ**ផឹកទឹកឲ្យបានច្រើន** ទឹកផ្លែឈើ ឬទឹកផ្សេងៗទៀត។ ចំពោះកុមារតូចៗ ជាពិសេសទារក គួរឲ្យផឹកទឹកដែលដាំឆ្អិន ហើយទុកឲ្យត្រជាក់។ ត្រូវប្រាកដថា កុមារមានបត់ជើងតូចយ៉ាងទៀងទាត់។ ប្រសិនបើកុមារមិនបត់ជើងតូចបានច្រើនទេ ឬទឹកនោមមានពណ៌ចាស់ ផ្តល់ទឹកឲ្យបានច្រើនថែមទៀត។

៤. បើអាចធ្វើបាន ស្វែងរកនិងព្យាបាលមូលហេតុដែលបណ្តាលឲ្យមានគ្រុនក្តៅនេះ។

# គ្រុនក្ដៅខ្លាំង

ការមានគ្រុនក្ដៅខ្លាំងអាចបណ្ដាលឲ្យមានគ្រោះថ្នាក់ ប្រសិនបើវាមិនថយចុះវិញឆាប់ៗទេ។ វាអាចបណ្ដាលឲ្យប្រកាច់ ឬធ្វើឲ្យខូចខួរក្បាលរហូត(ខ្វិន ប្រាជ្ញាអន់ថយ ឆ្កួតជ្រូក។ល។)។ គ្រុនក្ដៅខ្លាំងមានគ្រោះថ្នាក់បំផុតចំពោះកុមារតូចៗ។

**នៅពេលដែលគ្រុនក្ដៅកើនឡើង (លើសពី៤០ អង្សា) គេត្រូវបញ្ចុះកម្ដៅនោះជាបន្ទាន់ ៖**

១. ដាក់អ្នកជំងឺនៅកន្លែងដែលត្រជាក់។

២. ដោះសំលៀកបំពាក់គាត់ចេញទាំងអស់។

៣. បក់ឲ្យគាត់។

៤. ប្រោះទឹកត្រជាក់ល្មមលើខ្លួនគាត់ ឬយកក្រណាត់ជ្រលក់ទឹកត្រជាក់ល្មមហើយដាក់លើទ្រូងនិងថ្ងាសរបស់គាត់ ។ ត្រូវបក់ក្រណាត់នេះ និងប្ដូរវាឲ្យបានញឹកញាប់ ដើម្បីរក្សាវាឲ្យនៅត្រជាក់ល្មមដដែល។ ត្រូវបន្តធ្វើរបៀបនេះ រហូតដល់កម្ដៅចុះថយ (ក្រោម៣៨អង្សា)។




៥. ឲ្យគាត់ផឹកទឹកត្រជាក់ល្មមឲ្យបានច្រើន។

៦. ឲ្យថ្នាំបញ្ចុះកម្ដៅដល់គាត់ ។ អាស្ពីរីន ឬអាសេតាមីណូហ្វែន មានប្រសិទ្ធភាពល្អ។

*កម្រិតប្រើ* ៖ អាស្ពីរីន ឬអាសេតាមីណូហ្វែន(ប៉ារ៉ាសេតាមុល) (ដោយប្រើគ្រាប់ ៣០០មក្រ របស់មនុស្សធំ)

- មនុស្សដែលមានអាយុលើសពី១២ឆ្នាំ ៖ ប្រើ ២គ្រាប់ រៀងរាល់៤ម៉ោងម្ដង
- កុមារអាយុ ៦ទៅ១២ឆ្នាំ ៖ ប្រើ ១គ្រាប់ រៀងរាល់៤ម៉ោងម្ដង
- កុមារអាយុ ៣ទៅ៦ឆ្នាំ ៖ ប្រើកន្លះគ្រាប់ រៀងរាល់៤ម៉ោងម្ដង
- កុមារអាយុក្រោម ៣ឆ្នាំ ៖ ប្រើមួយភាគបួននៃគ្រាប់ រៀងរាល់៤ម៉ោងម្ដង

*ចំណាំ* ៖ ប៉ារ៉ាសេតាមុល មានសុវត្ថិភាពជាងអាស្ពីរីន សម្រាប់កុមារអាយុក្រោម ១២ឆ្នាំ ដែលមានជំងឺផ្ដាសាយ ហៀសំបោរ និងជំងឺអុតស្វាយ(ទំ.៣៧៩)។

ប្រសិនបើអ្នកជំងឺគ្រុនក្ដៅម្នាក់មិនអាចលេបថ្នាំគ្រាប់បាន កិនវា ហើយលាយវាជាមួយទឹក រួចបាញ់បញ្ចូលតាមរន្ធគូថ ដូចលាងពោះវៀនដែរ ឬដោយប្រើសឺរ៉ាំងដែលគ្មានម្ជុល។ វេជ្ជបណ្ឌិតខ្លះយល់ថា ថ្នាំអាសេតាមីណូហ្វែន ឬប៉ារ៉ាសេតាមុល ពុំមានគ្រោះថ្នាក់ដូចអាស្ពីរីនទេ ចំពោះកុមារតូចៗ។

**ប្រសិនបើគ្រុនក្ដៅមិនថយចុះយ៉ាងឆាប់ទេ ឬប្រសិនបើអ្នកជំងឺសន្លប់បាត់ស្មារតី ឬប្រសិនបើការប្រកាច់បានចាប់ផ្ដើមឡើង បន្តបញ្ចុះកម្ដៅដោយប្រើទឹក ហើយស្វែងរកជំនួយពីគ្រូពេទ្យជាបន្ទាន់។**

# ស្ទុក

ស្ទុកគឺជាស្ថានភាពមួយដែលគំរាមកំហែងដល់ជីវិត ដែលអាចបណ្តាលមកពីការរលាកយ៉ាងធ្ងន់ធ្ងរ ការបាត់បង់ឈាមជាច្រើន ការមានជំងឺធ្ងន់ ការខ្សោះជាតិទឹក ឬប្រតិកម្មអាល់ឡែស៊ីធ្ងន់ធ្ងរ។ ការហូរឈាមធ្ងន់ធ្ងរនៅខាងក្នុងរាងកាយ ទោះជាមើលមិនឃើញក៏ដោយ ក៏អាចបណ្តាលឲ្យមានស្ទុកបានដែរ។

*រោគសញ្ញាស្ទុក ៖*

- ជីពចរខ្សោយ ហើយញាប់(លើសពី១០០ក្នុងមួយនាទី)
- បែកញើសត្រជាក់ ស្លេកស្លាំង ខ្លួនត្រជាក់ ស្បែកសើម
- សម្ពាធឈាមធ្លាក់ចុះទាបគួរឲ្យគ្រោះថ្នាក់
- វង្វេងវង្វាយ ខ្សោយ បាត់បង់ស្មារតី

*តើត្រូវធ្វើអ្វីខ្លះដើម្បីបង្ការ ឬព្យាបាលស្ទុក ៖*



នៅចំពោះមុខរោគសញ្ញាដំបូងនៃស្ទុក ឬក្នុងករណីដែលអាចមានស្ទុក....

- ដាក់អ្នកជំងឺឲ្យដេក ក្នុងស្ថានភាពជើងខ្ពស់ជាងក្បាលបន្តិច ដូចក្នុងរូបភាពនេះ ។ ប៉ុន្តែ បើគាត់មានរបួសក្បាលធ្ងន់ធ្ងរ ដាក់គាត់ឲ្យដេកក្នុងស្ថានភាពពាក់កណ្តាលអង្គុយ(ទំ.៩១)
- បញ្ឈប់រាល់ការហូរឈាម។ ប្រើស្រោមដៃឬថង់ប្លាស្ទិកដើម្បីកុំឲ្យឈាមប្រឡាក់ដៃរបស់អ្នក។
- ប្រសិនបើអ្នកជំងឺមានអារម្មណ៍រងារ ដណ្តប់ភួយឲ្យគាត់។
- ប្រសិនបើគាត់នៅមានស្មារតីធម្មតា និងអាចផឹកទឹកបាន ត្រូវឲ្យគាត់ផឹកទឹកឬភេសជ្ជៈផ្សេងទៀត បន្តិចម្តងៗ។ បើគាត់ហាក់ដូចជាខ្សោះជាតិទឹក ផ្តល់ជាតិទឹកឲ្យច្រើន និងឲ្យទឹកអូរ៉ាលីត(ទំ.១៥២)។ ប្រសិនបើគ្មានការធូរស្រាលឆាប់ៗទេ ដាក់សេរ៉ូមឲ្យគាត់ ប្រសិនបើអ្នកចេះធ្វើ។
- ព្យាបាលរបួសរបស់គាត់ ប្រសិនជាមាន ។
- ប្រសិនបើគាត់មានការឈឺចាប់ ឲ្យថ្នាំអាស្ពីរីន ឬថ្នាំបំបាត់ការឈឺចាប់ផ្សេងទៀត។ ប៉ុន្តែមិនត្រូវឲ្យថ្នាំដែលមានសារធាតុដែលធ្វើឲ្យងងុយដេក ដូចជា កូដេអ៊ីន នោះទេ។
- រក្សាភាពស្ងៀមស្ងាត់ និងធ្វើឲ្យអ្នកជំងឺមានទំនុកចិត្ត ហើយរកជំនួយពីគ្រូពេទ្យ។

*បើអ្នកជំងឺសន្លប់បាត់ស្មារតី ៖*

- ដាក់ឲ្យគាត់ដេកផ្អៀងខ្លួន ដោយដាក់ក្បាលឲ្យទាប។ ប្រសិនបើគាត់ហាក់ដូចជាឈ្លក់ ត្រូវយកម្រាមដៃទាញអណ្តាតគាត់មកខាងមុខ។
- ប្រសិនបើគាត់ក្អួត ត្រូវសម្អាតមាត់គាត់ជាបន្ទាន់។ ត្រូវប្រាកដថាក្បាលរបស់គាត់នៅទាប ហើយងើយទៅក្រោយ និងបែរទៅម្ខាង(មើលរូបខាងលើ) ដើម្បីកុំឲ្យគាត់ដកដង្ហើមស្រូបកំអួតចូលទៅក្នុងសួត។ ប្រសិនបើគាត់មានរបួសកឬឆ្អឹងខ្នង កុំងើយក្បាល ឬរំកិលខ្លួនរបស់គាត់។
- មិនត្រូវផ្តល់អាហារតាមមាត់ទេ រហូតដល់ពេលដែលគាត់បានដឹងខ្លួនឡើងវិញ។
- បើអ្នក ឬអ្នកផ្សេងទៀតដែលនៅក្បែរនោះចេះ សូមបញ្ចូលសេរ៉ូម(ប្រៃធម្មតា)ដល់គាត់ ដោយបង្ហូរឲ្យលឿន។
- រកជំនួយពីគ្រូពេទ្យជាបន្ទាន់។

# ការបាត់ស្មារតី



មូលហេតុជាញឹកញាប់នៃការបាត់បង់ស្មារតី គឺ ៖

- ការស្រវឹងស្រា
- ការប៉ះទង្គិចក្បាល
- ស្ពុក (ទំ.៧៧ )
- ការពុល (ទំ.១០៣)
- គាំងបេះដូង(ទំ.៣២៥)
- ការងងឹតមុខ (ដោយការភ័យ ការអស់កម្លាំង)។ល។
- កម្តៅក្តៅខ្លាំង (ទំ.៨១)
- ដាច់សរសៃឈាមខួរក្បាល(ស្ពូក)(ទំ.៣២៧)
- ប្រកាច់(ទំ.១៧៨)

បើនរណាម្នាក់មានការបាត់បង់ស្មារតី ហើយអ្នកមិនដឹងថាមកពីមូលហេតុអ្វី **ត្រូវពិនិត្យមើលភ្លាមៗនូវចំនុចនីមួយៗ ដូចខាងក្រោម ៖**

១. តើគាត់**ដកដង្ហើម**បានស្រួលទេ? បើមិនស្រួលទេ ត្រូវផ្ងើយក្បាលគាត់ទៅក្រោយហើយទាញថ្គាមនិងអណ្តាតគាត់មកខាងមុខ។ បើមានអ្វីជាប់បំពង់ក ត្រូវទាញវាចេញ ។ បើគាត់មិនដកដង្ហើម ត្រូវអនុវត្តការផ្លុំដង្ហើមតាមមាត់ទល់នឹងមាត់ជាបន្ទាន់ ។ (ទំ.៨០)

២. តើគាត់មានហូរ**ឈាមច្រើនឬ**? ប្រសិនបើមាន ត្រូវបញ្ឈប់ការហូរឈាមនោះ។ (ទំ.៨២)

៣. តើគាត់ស្ថិតក្នុងសភាព**ស្ពុក**ឬ? (ខ្លួនត្រជាក់ ស្បែកស្លេកស្លាំង ជីពចរខ្សោយ ហើយញាប់)។ បើមាន ត្រូវដាក់គាត់ឲ្យដេកក្នុងស្ថានភាពក្បាលទាបជាងជើង ហើយបន្ធូរសំលៀកបំពាក់របស់គាត់(ទំ.៧៧)។

៤. តើមាន**ក្តៅសន្ទុំ**(មិនបែកញើស គ្រុនក្តៅខ្លាំង ស្បែកក្តៅនិងក្រហម?) ឬទេ? បើមាន យកគាត់ដាក់ក្នុងម្លប់ឲ្យផុតពីកម្តៅថ្ងៃ ដោយដាក់ក្បាលគាត់ឲ្យខ្ពស់ជាងជើង ហើយយកទឹកត្រជាក់មកលាបលើ ខ្លួនរបស់គាត់ (ទឹកកក បើមាន) ព្រមទាំងបក់ឲ្យគាត់ទៀត។

## ស្ថានភាពដេករបស់មនុស្សដែលបាត់បង់ស្មារតី

*ស្បែកស្លេកស្លាំងខ្លាំង (ស្ពុក ការដួលសន្លប់។ល។)*



*ស្បែកក្រហមឬធម្មតា (ក្តៅសន្ទុំ ស្ពូក ជំងឺបេះដូង របួសក្បាល)*



## ប្រសិនបើមានប្រការចៃដន្យណាមួយដែលអ្នកសន្លប់នោះមានរបួសជាទម្ងន់

ជាការប្រសើរបំផុត មិនត្រូវលើកគាត់ចុះឡើងទេ រហូតដល់គាត់ដឹងខ្លួនឡើងវិញ។ បើអ្នកត្រូវតែលើកគាត់ សូមធ្វើដោយប្រុងប្រយ័ត្នបំផុត ព្រោះបើ កឬឆ្អឹងខ្នងគាត់បាក់ នោះការផ្លាស់ប្តូរស្ថានភាពរបស់គាត់អាចធ្វើឲ្យមានរបួសកាន់តែធ្ងន់ធ្ងរថែមទៀត(ទំ.១០០)។

ពិនិត្យរកកន្លែងរបួស ឬឆ្អឹងដែលបាក់ ប៉ុន្តែធ្វើចលនាគាត់តិចតួចបំផុតតាមដែលអាចធ្វើបាន។ មិនត្រូវបត់ខ្នង ឬ ក របស់គាត់ទេ។

**មិនត្រូវផ្តល់អាហារតាមមាត់ ដល់អ្នកដែលបាត់បង់ស្មារតីទេ!!**

# ពេលដែលមានវត្ថុអ្វីមួយមកជាប់ក្នុងបំពង់ក



កំពុងស្ទះខ្យល់



កាលណាមានចំណីអាហារ ឬវត្ថុអ្វីផ្សេងទៀតជាប់ក្នុងបំពង់ក របស់នរណាម្នាក់ ហើយគាត់មិនអាចដកដង្ហើមបាន ត្រូវ**ប្រញាប់**ធ្វើដូចខាងក្រោមនេះ ៖

- ឈរពីក្រោយគាត់ហើយយកដៃមកអោបជុំវិញចង្កេះគាត់
- ដាក់កណ្ដាប់ដៃអ្នកទល់ពោះ នៅខាងលើផ្ចិត តែនៅក្រោមឆ្អឹងជំនីររបស់គាត់
- រួចសង្កត់លើពោះដោយកន្ត្រាក់ឡើងលើ**ឲ្យបានរហ័ស**ហើយខ្លាំងៗ ។ កម្លាំងនេះអាចធ្វើឲ្យខ្យល់ធាក់ចេញពីក្នុងសួត ហើយអាចរុញចំណីអាហារ ឬវត្ថុអ្វីផ្សេងទៀតចេញពីបំពង់ករបស់គាត់បាន។ ធ្វើរបៀបនេះជាច្រើនដង បើចាំបាច់។ បើមនុស្សនេះមានមាឌធំជាងអ្នក ឬសន្លប់បាត់ស្មារតី **ប្រញាប់**ធ្វើដូចខាងក្រោមនេះ ៖
- ដាក់គាត់ឲ្យដេកផ្ងារ។



- ផ្អៀងក្បាលគាត់ទៅចំហៀង។
- អង្គុយលើគាត់ដូចក្នុងរូបភាពនេះ ហើយសង្កត់កែងបាតដៃរបស់អ្នក លើពោះ ចន្លោះផ្ចិតនិងឆ្អឹងជំនីររបស់គាត់។ (ចំពោះមនុស្សធាត់ ស្ត្រីមានផ្ទៃពោះ ជនដែលអង្គុយលើរទេះរុញ ឬកុមារតូចៗ ត្រូវសង្កត់ដៃលើទ្រូងវិញ មិនមែនពោះទេ)។
- រុញឡើងលើឲ្យខ្លាំង យ៉ាងរហ័ស។
- ធ្វើរបៀបនេះជាច្រើនដង បើចាំបាច់។
- បើគាត់នៅតែមិនអាចដកដង្ហើមបាន សាកល្បង**ការផ្លុំដង្ហើមតាមមាត់ទល់មាត់**(មើលទំព័របន្ទាប់)។

# ការលង់ទឹក

មនុស្សដែលឈប់ដកដង្ហើម អាចរស់បានតែ៤នាទីប៉ុណ្ណោះ!! ។ **អ្នកត្រូវតែជួយឲ្យបានឆាប់រហ័សបំផុត!!**

ចាប់ផ្តើមការផ្លុំដង្ហើមតាមមាត់ទល់មាត់ភ្លាម(មើលទំព័របន្ទាប់) បើអាចធ្វើបាន ត្រូវធ្វើមុនពេលស្រង់អ្នកលង់ទឹកចេញពីទឹក នៅពេលមានកន្លែងទឹករាក់ល្មមដែលអាចឈរបាន។



បើអ្នកពុំអាចផ្លុំខ្យល់ចូលក្នុងសួតគាត់បានទេ នោះនៅពេលមកដល់ច្រាំង ត្រូវប្រញាប់ដាក់គាត់ដេកក្បាលទាបជាងជើង ហើយសង្កត់ទៅលើពោះ ដូចរៀបរាប់ខាងលើ។ បន្ទាប់មកត្រូវបន្តផ្លុំដង្ហើមតាមមាត់ទល់មាត់ភ្លាម។

**ត្រូវចាប់ផ្តើមការផ្លុំដង្ហើមតាមមាត់ទល់មាត់ភ្លាមៗ**
**មុនពេលព្យាយាមធ្វើឲ្យទឹកចេញពីទ្រូងរបស់អ្នកលង់ទឹក។**

# តើត្រូវធ្វើដូចម្តេចនៅពេលគ្មានការដកដង្ហើម ៖ ការផ្លុំដង្ហើមតាមមាត់ទល់មាត់

មូលហេតុជាញឹកញាប់នៃការឈប់ដកដង្ហើម មានដូចជា ៖

- មានវត្ថុអ្វីមួយជាប់ក្នុងបំពង់ក
- អណ្តាតឬស្លេសខាប់ធ្វើឲ្យស្ទះបំពង់ក នៃមនុស្សដែលសន្លប់បាត់ស្មារតី
- ការលង់ទឹក ការឈ្លក់ផ្សែង ឬការពុល
- ការប៉ះទង្គិចក្បាល ឬទ្រូងយ៉ាងខ្លាំង
- ការគាំងបេះដូង

មនុស្សយើងអាចស្លាប់ក្នុងរយៈពេល៤នាទី ប្រសិនបើគាត់មិនអាចដកដង្ហើមបាន។

**ប្រសិនបើនរណាម្នាក់ឈប់ដកដង្ហើម នោះត្រូវចាប់ផ្តើមផ្លុំដង្ហើមតាមមាត់ជាប្រញាប់ ។**



ធ្វើដូចខាងក្រោមនេះឲ្យរហ័សតាមដែលអ្នកអាចធ្វើបាន ៖

**ជំហានទី១.** ប្រើម្រាមដៃដើម្បីយកអ្វីដែលជាប់នៅក្នុងមាត់ឬក្នុងបំពង់កចេញជាបន្ទាន់។ ទាញអណ្តាតមកខាងមុខ។ បើមានស្លេសនៅក្នុងបំពង់ក ព្យាយាមសម្អាតវាចេញភ្លាម។



**ជំហានទី២.** ផ្ងារមុខអ្នកជំងឺឡើងលើដោយថ្នមៗ និងយ៉ាងឆាប់រហ័ស។ ផ្ងើយក្បាលគាត់ទៅក្រោយថ្នមៗ ហើយទាញថ្គាមមកមុខ។



**ជំហានទី៣.** យកម្រាមដៃច្របាច់ច្រមុះគាត់ ដោយបើកមាត់គាត់ឲ្យធំ ហើយដាក់មាត់របស់អ្នកពីលើមាត់របស់គាត់ ហើយផ្លុំខ្យល់ឲ្យខ្លាំងចូលទៅក្នុងសួតរបស់គាត់ ធ្វើដូច្នេះ ទ្រូងរបស់គាត់នឹងរីកប៉ោងឡើង។ បន្ទាប់មកត្រូវឈប់មួយភ្លែតសិន ដើម្បីទុកឲ្យខ្យល់ចេញមកវិញ ហើយផ្លុំខ្យល់ចូលម្តងទៀត។ ធ្វើដូចនេះរៀងរាល់ ៥វិនាទីម្តង។ ចំពោះទារកនិងកុមារ ត្រូវច្របាច់ច្រមុះរបស់វា ហើយប្រើវិធីផ្លុំមាត់ទល់មាត់ដោយ**ថ្នមៗ**បំផុតប្រហែល ៣វិនាទីម្តង។

បន្ត**ការផ្លុំដង្ហើមតាមមាត់ទល់មាត់** រហូតដល់អ្នកជំងឺអាចដកដង្ហើមដោយខ្លួនឯងបាន ឬត្រូវបន្តធ្វើរហូតដល់គ្មានការសង្ស័យថា គាត់បានស្លាប់ហើយ។ ជួនកាលអ្នកត្រូវបន្តព្យាយាមធ្វើបៀបនេះរហូតដល់១ម៉ោងឬលើសពីនេះ។

# ករណីបន្ទាន់ដែលបណ្ដាលមកពីកម្ដៅ

## ការចុករមួលដោយសារកម្ដៅ



នៅក្នុងអាកាសធាតុក្ដៅ អ្នកដែលប្រឹងប្រែងធ្វើការខ្លាំងហើយបែកញើសច្រើន ជួនកាលធ្វើឲ្យពួកគេ មានការឈឺចុកចាប់ជើង ដៃឬក្រពះ។ បញ្ហានេះកើតឡើងដោយសាររាងកាយខ្វះជាតិអំបិល។

*ការព្យាបាល* ៖ ដាក់អំបិលមួយស្លាបព្រាកាហ្វេចូលទៅក្នុងទឹកដាំឆ្អិន១លីត្រ ហើយផឹកទឹកនោះ។ ត្រូវផឹកទឹកអំបិលនោះរៀងរាល់មួយម៉ោងម្ដង រហូតដល់ការចុករមួលនោះបានធូរស្រាល។ ឲ្យអ្នកនោះអង្គុយ ឬសម្រាកនៅកន្លែងត្រជាក់ល្មម ហើយម៉ាសាកន្លែងដែលចុករមួលនោះដោយថ្នមៗ។

## ការខ្សោះកម្លាំងដោយសារកម្ដៅ

*រោគសញ្ញា* ៖ អ្នកដែលធ្វើការងារក្រោមកម្ដៅថ្ងៃ ហើយមានបែកញើសយ៉ាងច្រើន អាចមានភាពស្លេកស្លាំង ខ្សោយ និងចង់ក្អួត ហើយអាចដួលសន្លប់ទៀតផង។ ស្បែកត្រជាក់ ហើយសើម។ ជីពចរដើរញាប់ ហើយខ្សោយ។ ជាទូទៅសីតុណ្ហភាពរាងកាយមានសភាពធម្មតា(ទំ.៣១)។

*ការព្យាបាល* ៖ ដាក់អ្នកនោះឲ្យដេកនៅកន្លែងត្រជាក់ ដោយលើកជើងគាត់ឡើងលើ ហើយច្របាច់ជើងរបស់គាត់។ ឲ្យគាត់ផឹកទឹកដែលមានអំបិលមួយស្លាបព្រាកាហ្វេលាយជាមួយនឹងទឹកមួយលីត្រ។ (មិនត្រូវឲ្យអ្វីដល់អ្នកជំងឺតាមមាត់ នៅពេលដែលអ្នកនោះសន្លប់បាត់ស្មារតីទេ។)

## ក្ដៅសន្ធំ

ក្ដៅសន្ធំគឺជាជំងឺដែលមិនសូវកើតមានទេ តែវាជាជំងឺដែលមានគ្រោះថ្នាក់ណាស់។ វាតែងកើតឡើងជាពិសេសចំពោះមនុស្សចាស់ និងអ្នកដែលផឹកស្រាច្រើន ក្នុងពេលអាកាសធាតុក្ដៅ។

*រោគសញ្ញា* ៖ ស្បែកឡើងក្រហម ក្ដៅខ្លាំង និងស្ងួត។ សូម្បីតែក្លៀកក៏មិនមានសំណើមដែរ។ អ្នកជំងឺប្រភេទនេះមានគ្រុនក្ដៅខ្លាំង ជួនកាលមានសីតុណ្ហភាពឡើងដល់ ៤២អង្សា។ ជាទូទៅគាត់តែងសន្លប់បាត់ស្មារតីនៅពេលនោះ។

*ការព្យាបាល* ៖ **គេត្រូវតែបញ្ចុះសីតុណ្ហភាពជាបន្ទាន់។** ត្រូវដាក់អ្នកជំងឺនៅកន្លែងដែលមានម្លប់។ ជូតខ្លួនជាមួយទឹកត្រជាក់(ទឹកកកក៏បាន បើអាច) ហើយបក់ឲ្យគាត់រហូតដល់គ្រុនក្ដៅបានថយចុះ។ បន្ទាប់មកស្វែងរកជំនួយពីគ្រូពេទ្យ។ សម្រាប់ការសង្គ្រោះបន្ទាន់ ចំពោះបញ្ហាដែលបណ្ដាលមកពីការត្រជាក់ សូមមើលទំព័រ៤០៨ និង៤០៩។

ភាពខុសគ្នារវាងការខ្សោះកម្លាំងដោយសារកម្ដៅ និងក្ដៅសន្ធំ

**ការខ្សោះកម្លាំងដោយសារកម្ដៅ**

- បែកញើស ស្លេកស្លាំង ស្បែកត្រជាក់
- កូនក្រមុំភ្នែករីកធំ
- គ្មានគ្រុនក្ដៅ
- ខ្សោយកម្លាំង



**ក្ដៅសន្ធំ**

- ស្បែកស្ងួត ក្រហម និងក្ដៅ
- គ្រុនក្ដៅខ្លាំង
- អ្នកជំងឺឈឺធ្ងន់ ឬបាត់ស្មារតី

# វិធីឃាត់ឈាមដែលហូរពីរបួស

១. លើកកន្លែងដែលមានរបួសឡើង ។

២. យកក្រណាត់ដែលក្រាសហើយស្អាត (ឬប្រើដៃរបស់អ្នកផ្ទាល់ បើគ្មានក្រណាត់) សង្កត់ដោយផ្ទាល់លើមុខរបួស ហើយបន្តសង្កត់រហូតដល់ឈាមឈប់ហូរ។ គេអាចធ្វើដូច្នេះក្នុងរយៈពេល២០នាទី និងពេលខ្លះអាចប្រើរយៈពេលដល់មួយម៉ោងឬច្រើនជាងនេះ។ វិធីសង្កត់បែបនេះនឹងអាចឃាត់ឈាមដែលហូរពីស្ទើរតែគ្រប់មុខរបួសទាំងអស់។ ពោលគឺ ជួនកាលក៏អាចឃាត់ឈាមបានដែរ នៅពេលដែលផ្នែកណាមួយនៃរាងកាយត្រូវបានដាច់ចេញផង។



ជួនកាល ការសង្កត់ដោយផ្ទាល់នេះនឹងមិនអាចជួយឃាត់ឈាមបានទេ ជាពិសេសនៅពេលដែលមានមុខរបួសធំពេក ឬនៅពេលដែលដៃឬជើងរបស់គេត្រូវបានដាច់ចេញ។ ប្រសិនបើបញ្ហានេះកើតឡើង ហើយអ្នករងរបួសនោះស្ថិតក្នុងសភាពគ្រោះថ្នាក់នៃការហូរឈាមរហូតដល់ស្លាប់ នោះសូមធ្វើតាមវិធីដូចខាងក្រោម ៖

*ចំណុចសង្កត់*



- ត្រូវបន្តសង្កត់លើមុខរបួស។
- លើកអវយវៈដែលមានរបួសឲ្យបានខ្ពស់តាមដែលអាចធ្វើបាន។
- អ្នកអាចរក្សាការសង្កត់ដោយការរុំមុខរបួសនោះយ៉ាងតឹងជាមួយបង់រុំ ឬជាមួយក្រណាត់ស្អាត។
- ច្របាច់ត្រង់ចំណុចសង្កត់លើសរសៃអាទែដែលនាំឈាមទៅកាន់ផ្នែកនៃរាងកាយដែលមានរបួសនោះ។ ចំណុចសង្កត់គឺជាកន្លែងដែលអ្នកអាចសង្កត់សរសៃអាទែផ្ទប់ទៅលើឆ្អឹង ដោយប្រើផ្នែកដែលរាបស្មើនៃម្រាមដៃអ្នក ដើម្បីបិទ ឬបន្ថយការហូរឈាម។



- បន្តការសង្កត់រយៈពេល២០នាទី មុននឹងពិនិត្យមើលថាតើឈាមឈប់ហូរឬនៅ។ ដៃម្ខាងទៀតបន្តសង្កត់លើមុខរបួសដដែល។

*ការប្រុងប្រយ័ត្ន ៖*

- មិនត្រូវប្រើប្រដាប់កៀបសរសៃឈាម ខ្សែ ឬលួស ដើម្បីបញ្ឈប់ការហូរឈាមនោះទេ។ ការធ្វើរបៀបនេះភាគច្រើនបណ្ដាលឲ្យខូចដៃឬជើងនោះទាំងស្រុងតែម្ដង។
- **មិនត្រូវ**ប្រើសំរាម ប្រេងកាត កំបោរ ឬកាហ្វេ ដើម្បីឃាត់ឈាមឡើយ។
- នៅពេលដែលការហូរឈាម ឬមុខរបួសមានសភាពធ្ងន់ធ្ងរ លើកជើងឡើងលើ ហើយដាក់ក្បាលឲ្យទាប ដើម្បីបង្ការស្ហុក(ទំ.៧៧)។
- មិនត្រូវឲ្យមានឈាមរបស់ជនរងគ្រោះចូលក្នុងមុខរបួស ឬដំបៅរបស់អ្នកទេ។

# របៀបឃាត់ឈាមច្រមុះ



១. អង្គុយឲ្យស្ងៀម។

២. ដកដង្ហើមធំដោយថ្នមៗដើម្បីបញ្ចេញសំបោរនិងឈាមពីច្រមុះ។

៣. ច្របាច់ច្រមុះឲ្យណែនរយៈពេល ១០នាទី ឬរហូតដល់ឈាមឈប់ហូរ។



បើការធ្វើដូចនេះ មិនអាចឃាត់ឈាមបាន.....



ចុករន្ធច្រមុះដោយដុំសំឡី ដោយទុកឲ្យសល់សំឡីខ្លះនៅខាងក្រៅច្រមុះ។ ប្រសិនបើអាច ត្រូវជ្រលក់សំឡីនោះជាមួយ**វ៉ាស៊ីលីន** ឬលីដូកាអ៊ីន ដែលមានអេពីណេហ្វ្រីន(Epinephrine) (ទំ.៣៨១)ជាមុនសិន។

បន្ទាប់មក ច្របាច់ច្រមុះឲ្យណែនម្តងទៀត។ មិនត្រូវលែងវិញក្នុងរយៈពេល ១០នាទី ឬលើសពីនេះ។ មិនត្រូវទះក្បាលទៅក្រោយទេ។



ទុកដុំសំឡីនៅក្នុងច្រមុះរយៈពីរបីម៉ោង បន្ទាប់ពីឈាមឈប់ហូរ។ បន្ទាប់មកយកវាចេញដោយប្រុងប្រយ័ត្នបំផុត។

ចំពោះមនុស្សចាស់ ជាពិសេស ឈាមអាចហូរពីផ្នែកខាងក្រោយនៃច្រមុះ ហើយមិនអាចឃាត់បានដោយការច្របាច់ច្រមុះនោះទេ។ ក្នុងករណីនេះ ឲ្យគាត់ខាំឆ្នុកដប ស្នូលពោត ឬវត្ថុអ្វីដែលស្រដៀងគ្នានេះនៅចន្លោះធ្មេញរបស់គាត់ ហើយអោនទៅមុខបន្តិច អង្គុយឲ្យស្ងៀមហើយព្យាយាមកុំឲ្យលេប រហូតដល់ឈាមឈប់ហូរ។ (ឆ្នុកដបអាចជួយមិនឲ្យគាត់លេប ហើយទុកឱកាសឲ្យឈាមកក។)

*វិធីបង្ការ ៖*

ប្រសិនបើនរណាម្នាក់មានការហូរឈាមច្រមុះជាញឹកញាប់ ឲ្យគាត់លាបវ៉ាស៊ីលីនបន្តិចនៅខាងក្នុងរន្ធច្រមុះពីរដងក្នុងមួយថ្ងៃ ឬហឺតទឹកមានជាតិអំបិលបន្តិច(ទំ.១៦៤)។

ការបរិភោគផ្លែក្រូច ប៉េងប៉ោះ និងផ្លែឈើដទៃទៀត អាច**ជួយពង្រឹងសរសៃវ៉ែន ហើយធ្វើឲ្យមិនសូវមានការហូរឈាមតាមច្រមុះ។**

# ការមុត ការរលាត់ និងរបួសតូចៗ

**អនាម័យគឺជាការសំខាន់បំផុតក្នុងការបង្ការការបង្ករោគ និងជួយធ្វើឲ្យរបួសឆាប់ជាសះ។**

**ដើម្បីព្យាបាលរបួស....**



ដំបូង លាងដៃរបស់អ្នកឲ្យបានស្អាតជាមួយសាប៊ូ និងទឹក។

បន្ទាប់មក លាងស្បែកដែលនៅជុំវិញមុខរបួស ដោយប្រើសាប៊ូ និងទឹកឆ្អិន។

ឥឡូវនេះ លាងសម្អាតមុខរបួស ជាមួយទឹកឆ្អិន( និងសាប៊ូ បើរបួសនោះមានជាប់សំរាម។ សាប៊ូជួយសម្អាត ប៉ុន្តែវាអាចធ្វើឲ្យខូចសាច់ដុំ)។



នៅពេលលាងសម្អាតមុខរបួស ត្រូវយកចិត្តទុកដាក់សម្អាតឲ្យអស់ភាពកខ្វក់ដែលមាននៅរបួសនោះ។ បើកមុខរបួស ហើយ លាងសម្អាតនៅខាងក្នុងមុខរបួស។ អ្នកអាចប្រើដង្កៀបដែលស្អាត ឬក្រណាត់ស្អាត ឬកុំប្រេស ដើម្បីយកភាពកខ្វក់ចេញ ប៉ុន្តែត្រូវស្ងោរសម្ភារៈទាំងនោះជាមុនសិន ដើម្បីធានាថាវាស្ទេរីល។



បើអាចធ្វើបាន បង្ហើបមុខរបួស ហើយបាញ់ទឹកឆ្អិនដោយសឺរ៉ាំង ឬប្រដាប់បូម។

រាល់ភាពកខ្វក់ដែលនៅសល់ក្នុងរបួស អាចធ្វើឲ្យមានការបង្ករោគបាន។

បន្ទាប់ពីបានលាងមុខរបួសហើយ ដាក់កុំប្រេសឬក្រណាត់ស្អាតនៅលើមុខរបួសនោះ។ កុំប្រេសឬក្រណាត់ស្អាតនោះ គួរស្តើងល្មមដែលអាចឲ្យខ្យល់អាចចូលដល់មុខរបួសបាន និងជួយឲ្យរបួសឆាប់ផ្សះ។ ផ្លាស់ប្តូរកុំប្រេសឬក្រណាត់រុំនោះជារៀងរាល់ថ្ងៃ ហើយរកមើលរោគសញ្ញានៃការបង្ករោគផង( ទំ.៨៨ )។

**មិនត្រូវដាក់លាមកមនុស្សឬលាមកសត្វ ឬភក់នៅលើមុខរបួសទេ។ វត្ថុទាំងនេះអាចបណ្តាលឲ្យមានការបង្ករោគដ៏គ្រោះថ្នាក់បាន ដូចជាតេតាណូសជាដើម។**

**មិនត្រូវដាក់អាល់កុល ឬទឹកថ្នាំអ៊ីយ៉ូដ ឬមេធ្យូឡាត ដោយផ្ទាល់ទៅលើរបួសនោះឡើយ។ ការធ្វើដូច្នេះ នឹងធ្វើឲ្យប៉ះពាល់ដល់សាច់ និងធ្វើឲ្យមុខរបួសផ្សះយឺត។**

# របួសធំ ៖ របៀបបិទមុខរបួស

របួសថ្មីៗ ដែលស្អាត នឹងអាចជាសះយ៉ាងឆាប់រហ័ស បើគេអាចផ្គុំគែមមុខរបួសនោះចូលគ្នាបាន។ ការធ្វើដូចនេះ ធ្វើឲ្យមុខរបួសបិទជិត។

ការភ្ជិតមុខរបួសដែលជ្រៅ អាចធ្វើទៅបាន តែក្នុងករណីដូចខាងក្រោមនេះ ៖

- របួសមានរយៈពេលតិចជាង១២ម៉ោង
- របួសមានសភាពស្អាត និង
- មិនអាចរកបុគ្គលិកសុខាភិបាល ដើម្បីភ្ជិតមុខរបួសក្នុងថ្ងៃនោះ។

មុនភ្ជិតមុខរបួស ត្រូវលាងវាឲ្យស្អាតជាមួយទឹកឆ្អិនត្រជាក់ (និងសាប៊ូ ប្រសិនបើរបួសនោះកខ្វក់)។ បើអាចធ្វើបាន ត្រូវបង្ហើបមុខរបួស ហើយបាញ់ទឹកលាងដោយប្រើសឺរ៉ាំង។ ត្រូវប្រាកដថា គ្មានកំទេចធូលី ឬសាប៊ូនៅសល់ក្នុងរបួសនោះឡើយ។

មានរបៀបពីរយ៉ាងដើម្បីបិទមុខរបួស ៖

បង់ស្អិតមានរាងដូចមេអំបៅ



# ការដេរបិទមុខរបួសដោយប្រើអំបោះ

ដើម្បីឲ្យដឹងថាតើមុខរបួសត្រូវការដេរឬទេ គេត្រូវមើលសិន ថាតើគែមស្បែកនៃមុខរបួសនោះបិទជាប់គ្នាដោយឯកឯងឬទេ។ ជាទូទៅ ប្រសិនបើគែមស្បែកនៃមុខរបួសនោះបិទជាប់គ្នាដោយឯកឯង គេមិនចាំបាច់ដេរវាទេ។

ដើម្បីដេរមុខរបួស ៖

- ស្ងោរម្ជុលដេរ និងអំបោះឆ្មារ ( នីឡុង ឬសរសៃសូត្រ គឺជាការប្រសើរ ) រយៈពេល២០នាទី។
- លាងមុខរបួសជាមួយទឹកឆ្អិនដែលត្រជាក់ល្មម ដូចបានរៀបរាប់ខាងលើ។
- លាងដៃរបស់អ្នកឲ្យស្អាតដោយប្រើទឹកឆ្អិននិងសាប៊ូ។
- ដេរមុខរបួសដូចខាងក្រោមនេះ ៖



*របៀបចងចំណងដែលល្អ*



ដេរថ្នេរទីមួយនៅចំពាក់កណ្ដាលមុខរបួស រួចចងឲ្យជិតមុខ។ (រូបភាព១និង២។)

ប្រសិនបើស្បែកស្វិត ប្រើដង្កៀបដែលបានស្ងោរហើយ ដើម្បីគៀបម្ជុល។

ដេរថ្នេរបន្តទៀត តាមដែលត្រូវការដើម្បីភ្ជិតមុខរបួសទាំងមូល។ (រូបភាពទី៣។)

ទុកថ្នេរទាំងអស់ឲ្យបាន៥ថ្ងៃទៅ ១៤ថ្ងៃ។ (របួសនៅមុខ ទុក៥ថ្ងៃ របួសនៅលើខ្លួនប្រាណ១០ថ្ងៃ និងនៅលើដៃ ឬជើង ១៤ថ្ងៃ)។ បន្ទាប់មក កាត់ថ្នេរចេញ ៖ កាត់អំបោះនៅផ្នែកម្ខាងនៃចំណង ហើយទាញហូតអំបោះតាមចំណង រហូតដល់អំបោះចេញអស់ពីមុខរបួស។

*ការប្រុងប្រយ័ត្ន* ៖ ដេរបិទតែមុខរបួសណាដែលស្អាតបំផុត ហើយស្ថិតក្នុងរយៈពេលតិចជាង១២ម៉ោង។ របួសចាស់កខ្វក់ ឬរបួសដែលមានការបង្ករោគ ត្រូវទុកឲ្យនៅចំហ។ របួសដោយមនុស្សខាំ ឆ្កែខាំ ជ្រូកខាំ ឬសត្វដ៏ទៃទៀតខាំ ក៏ត្រូវទុកឲ្យនៅចំហដែរ។ ការដេរបិទរបួសទាំងនេះ អាចបណ្ដាលឲ្យមានការបង្ករោគដ៏គ្រោះថ្នាក់។

**បើរបួសដែលបានដេរបិទហើយនោះ បង្ហាញរោគសញ្ញានៃការបង្ករោគ ត្រូវប្រញាប់កាត់ថ្នេរចេញភ្លាមៗ ហើយទុកមុខរបួសនោះឲ្យនៅចំហ( ទំ.៨៨ )។**

# បង់រុំរបួស

បង់រុំរបួស ត្រូវបានប្រើដើម្បីជួយរក្សារបួសឲ្យនៅស្អាត។ សម្រាប់មូលហេតុនេះ បង់រុំរបួសឬក្រណាត់ដែលត្រូវបានប្រើ ដើម្បីរុំរបួសក៏ត្រូវតែស្អាតជានិច្ចដែរ។ ក្រណាត់ដែលប្រើសម្រាប់រុំរបួស ត្រូវបោកសម្អាត ហើយទុកឲ្យស្ងួត ដោយការអ៊ុត ឬដាក់ហាលថ្ងៃ នៅកន្លែងដែលស្អាត គ្មានធូលីដី។

ត្រូវប្រាកដថា មុខរបួសត្រូវបានលាងសម្អាតជាមុន ដូចបានបង្ហាញនៅ ទំ.៨៤។ បើអាចធ្វើបាន គ្របមុខរបួស ដោយដុំកុំប្រេសស្តេរីលសិន មុននឹងរុំបង់រុំរបួស។ ដុំកុំប្រេសនេះតែងមានលក់ជាកញ្ចប់ដែលបិទជិតនៅតាមឱសថស្ថាននានា។

ឬអ្នកអាចរៀបចំកុំប្រេសស្តេរីល ឬក្រណាត់នោះដោយខ្លួនឯង។ ខ្ចប់កុំប្រេស ឬក្រណាស់នៅក្នុងក្រដាស់ក្រាស់រួចបិទឲ្យជិត ដោយបង់ស្អិត ហើយចំហុយវាក្នុងរយៈពេល២០នាទីក្នុងឆ្នាំងចំហុយ។ ការដាក់ទឹកមួយចានដែកទៅក្នុងឆ្នាំងចំហុយ កុំឲ្យដល់កញ្ចប់កុំប្រេស នឹងជួយការពារកុំឲ្យឆេះកញ្ចប់នោះ។

**ការមិនប្រើបង់រុំទាល់តែសោះប្រសើរជាងការប្រើបង់រុំដែលកខ្វក់ ឬសើម។**

ប្រសិនបើបង់រុំរបួសនោះសើម ឬកខ្វក់ ដោះវាចេញ ហើយលាងមុខរបួសនោះម្តងទៀត បន្ទាប់មករុំបង់រុំដែលស្អាត។ ផ្លាស់ប្តូរបង់រុំជារៀងរាល់ថ្ងៃ។

នេះជាឧទាហរណ៍នៃការរុំរបួស ៖





*កំណត់សំគាល់ ៖* ចំពោះកុមារ វាជាការប្រសើរក្នុងការរុំដៃ ឬជើងទាំងមូល ជំនួសឲ្យការរុំតែម្រាមដៃ ឬម្រាមជើង ដើម្បីកុំឲ្យវារបូតចេញដោយងាយៗ។

*ការប្រុងប្រយ័ត្ន ៖*

ប្រុងប្រយ័ត្នចំពោះការរុំព័ទ្ធជុំវិញអវយវៈ។ មិនត្រូវរុំតឹងពេក រហូតដល់វាអាចកាត់ផ្តាច់ការហូរនៃឈាមទេ។

មានការរលាត់ និងការមុតតូចៗជាច្រើនមិនត្រូវការការរុំទេ។ របួសទាំងនោះអាចជាសះស្បើយបាន ប្រសិនជាគេលាងវាជាមួយសាប៊ូ និងទឹក ហើយទុកវាចំហឲ្យត្រូវខ្យល់។ អ្វីដែលសំខាន់បំផុត គឺត្រូវ**រក្សាវាឲ្យស្អាត**ជានិច្ច។

# ដំបៅក្លាយ ៖
# វិធីសំគាល់ និងព្យាបាល

**ដំបៅមួយជាដំបៅក្លាយ (មានការបង្ករោគ) ប្រសិនបើ**

- វាឡើង**ក្រហម ហើម ក្តៅ** និង**ឈឺចាប់**
- វាមានខ្ទុះ
- ឬបើវាចាប់ផ្តើមមាន**ក្លិនស្អុយ**

**ការបង្ករោគនេះនឹងឆ្លងរាលដាលដល់កន្លែងផ្សេងទៀតនៃរាងកាយ ប្រសិនបើ**

- វាធ្វើឲ្យមាន**គ្រុនក្តៅ**
- មានឡើង**ឆ្នូតក្រហមនៅខាងលើមុខរបួស**
- ឬបើមាន**ហើមកូនកណ្តុរហើយឈឺ។** កូនកណ្តុរ ជាញឹកញាប់ត្រូវបានគេហៅថា ក្រពេញ - គឺជាអន្ទាក់តូចៗ សម្រាប់ដាក់មេរោគ ដែលបង្កើតបានជាដុំតូចៗនៅខាងក្រោមស្បែក នៅពេលដែលវាមានបង្ករោគ។



ការហើមកូនកណ្តុរនៅខាងក្រោយត្រចៀក គឺជារោគសញ្ញានៃការបង្ករោគនៅក្បាល ឬនៅលលាដ៏ក្បាល ដែលជាញឹកញាប់បណ្តាលមកពីមានដំបៅ ឬចៃ។ ឬអាចជាមូលហេតុនៃការចេញកញ្ជ្រឹលអាល្លឺម៉ង់។

ការហើមកូនកណ្តុរនៅខាងក្រោមត្រចៀក និងនៅកញ្ចឹងក បញ្ជាក់ថាមានការបង្ករោគនៅត្រចៀក មុខ ឬនៅក្បាល (ឬជាជំងឺរបេង)។

ការហើមកូនកណ្តុរនៅខាងក្រោមថ្គាម បញ្ជាក់ថាមានការបង្ករោគនៅធ្មេញ ឬនៅបំពង់ក។

ការហើមកូនកណ្តុរនៅក្លៀក បញ្ជាក់ថាមានការបង្ករោគនៅដៃ ក្បាល ឬនៅដោះ (ជួនកាល មហារីកដោះ)។

ការហើមកូនកណ្តុរនៅក្រលៀន បញ្ជាក់ថាមានការបង្ករោគនៅជើង ឬប្រអប់ជើង ប្រដាប់បន្តពូជ ឬរន្ធគូទ។

*វិធីព្យាបាលដំបៅក្លាយ ៖*

- ដាក់កុំប្រេសក្តៅឧណ្ហៗរយៈពេល២០នាទី ៤ដងក្នុងមួយថ្ងៃ។ ត្រាំដៃ ឬជើងដែលមានការបង្ករោគនៅក្នុងធុងទឹកក្តៅឧណ្ហៗ។
- ដាក់ផ្នែកនៃរាងកាយដែលមានបង្ករោគឲ្យសម្រាក និងលើកឲ្យខ្ពស់(លើកឲ្យខ្ពស់ជាងកម្រិតកម្ពស់របស់បេះដូង)។
- ប្រសិនបើការបង្ករោគនោះធ្ងន់ធ្ងរ ឬប្រសិនបើអ្នកជំងឺមិនដែលបានទទួលការចាក់វ៉ាក់សាំងបង្ការជំងឺតេតាណូសទេ ប្រើថ្នាំអង់ទីប៊ីយ៉ូទិក ដូចជាថ្នាំប៉េនីស៊ីលីន(ទំ.៣៥១ និង៣៥២) និងមេត្រូនីដាហ្សូល(ទំ.៣៦៩) ផងដែរ។

*ការប្រុងប្រយ័ត្ន* ៖ ប្រសិនបើដំបៅមានក្លិនស្អុយ មានខ្ទុះពណ៌ត្នោត ឬពណ៌ប្រផេះហូរចេញមកក្រៅ ឬស្បែកជុំវិញរបួសឡើងពណ៌ខ្មៅ ហើយមានពពុះឬមានពងបែក នោះវាអាចជាហ្គង់ហ្គ្រែន(ដំបៅរលួយ)។ ត្រូវស្វែងរកជំនួយពីគ្រូពេទ្យជាបន្ទាន់។ ក្នុងពេលជាមួយគ្នានោះដែរ ធ្វើតាមការណែនាំអំពីដំបៅរលួយ នៅទំ.២១៣។

# របួសដែលទំនងជាងាយមានការបង្ករោគដ៏គ្រោះថ្នាក់

**របួសដែលទំនងជាងាយក្លាយជាមានការបង្ករោគដ៏មានគ្រោះថ្នាក់ទាំងនេះមាន**

- របួសកខ្វក់ ឬរបួសដែលបង្កដោយវត្ថុកខ្វក់
- របួសរាក់និងរបួសជ្រៅដែលមិនសូវហូរឈាមច្រើន
- របួសដែលកើតឡើងនៅកន្លែងចិញ្ចឹមសត្វ ៖ ដូចជានៅក្រោល ឬទ្រុងជ្រូក ជាដើម
- របួសធំៗដែលមានការខ្ទេចខ្ទាំ ឬមានជាំធ្ងន់ធ្ងរ
- របួសដោយការខាំ ជាពិសេសជ្រូក ឆ្កែ ឬមនុស្សខាំ
- របួសដោយគ្រាប់កាំភ្លើង



**ការថែទាំពិសេសសម្រាប់ប្រភេទរបួសដែលប្រឈមនឹងគ្រោះថ្នាក់ខ្ពស់នេះគឺ**

១. លាងរបួសឲ្យស្អាតជាមួយទឹកឆ្អិននិងសាប៊ូ។ **យកចេញឲ្យអស់នូវកំទេចសំរាម ដុំកំណកឈាម និងសាច់ដែលងាប់ ឬស្បែកដែលខ្ទេចខ្ទាំខ្លាំង។** បាញ់ទឹកលាងចេញឲ្យអស់នូវអ្វីដែលកខ្វក់ ដោយប្រើសឺរ៉ាំងឬប្រដាប់បូម។

២. ប្រសិនបើជាមុខរបួសជ្រៅ ជារបួសដោយការខាំ ឬបើសង្ស័យថានៅមានភាពកខ្វក់នៅក្នុងរបួសទៀត ឲ្យថ្នាំអង់ទីប៊ីយ៉ូទិក ដូចជាសែហ្វទ្រីយ៉ាហ្សូន(Ceftriaxone) ឬថ្នាំសេហ្វាឡូស្ពូរីន (Cephalosporin) ផ្សេងទៀតដូចជារយៈពេល ៣ទៅ៧ថ្ងៃ(ទំ.៣៥៩)។ ប្រសិនបើអ្នកគ្មានថ្នាំប្រភេទនេះទេ អាចឲ្យថ្នាំ អេរីត្រូមីស៊ីន (Erythromycin) (ទំ.៣៥៥) និងថ្នាំសុលហ្វាមេតុកសាសូល រួមជាមួយ ទ្រីមេតូព្រីម (កូទ្រីម Cotrim ទំ.៣៥៨) ឬថ្នាំសុលហ្វា(Sulfa ទំ.៣៥៨)។

៣. **មិនត្រូវ**បិទមុខរបួសប្រភេទនេះដោយការដេរ ឬដោយប្រើបង់រុំរាងដូចមេអំបៅនោះទេ។ ទុកមុខរបួសឲ្យនៅចំហ។ ប្រសិនបើមុខរបួសធំពេក បុគ្គលិកសុខាភិបាលដែលមានជំនាញ ឬវេជ្ជបណ្ឌិតអាចដេរភ្ជិតវានៅពេលតក្រោយបាន។

គ្រោះថ្នាក់នៃជំងឺតេតាណូស គឺធ្ងន់ធ្ងរណាស់ចំពោះមនុស្សដែលមិនបានទទួលការចាក់ថ្នាំបង្ការជំងឺដ៏សាហាវនេះ។ ដើម្បីកាត់បន្ថយការប្រឈមនឹងគ្រោះថ្នាក់ អ្នករបួសដែលមិនបានទទួលការចាក់វ៉ាក់សាំងបង្ការជំងឺតេតាណូស ត្រូវប្រើថ្នាំប៉េនីស៊ីលីន ឬអំពីស៊ីលីនភ្លាមៗ បន្ទាប់ពីមានរបួសប្រភេទនេះ ទោះបីជារបួសនោះតូចក៏ដោយ។

បើរបួសប្រភេទនេះមានសភាពធ្ងន់ធ្ងរ អ្នកដែលមិនបានចាក់វ៉ាក់សាំងបង្ការជំងឺតេតាណូស ត្រូវប្រើថ្នាំប៉េនីស៊ីលីន ឬអំពីស៊ីលីន ក្នុងកម្រិតខ្ពស់ រយៈពេលមួយអាទិត្យឬលើសពីនេះ។ អ្នកក៏អាចពិចារណាអំពីការប្រើថ្នាំអង់ទីតុកស៊ីន(anti toxin) សម្រាប់ តេតាណូស ដែរ ប៉ុន្តែត្រូវមានការប្រុងប្រយ័ត្ន(ទំ.៧០) ប្រសិនបើប្រើថ្នាំអង់ទីតុកស៊ីនដែលផលិតពីសេរ៉ូមសេះ។

# របួសដោយគ្រាប់កាំភ្លើង កាំបិត និងរបួសធ្ងន់ធ្ងរផ្សេងទៀត



*គ្រោះថ្នាក់នៃការបង្ករោគ* ៖ របួសជ្រៅដោយគ្រាប់កាំភ្លើង ឬកាំបិត អាចធ្វើឲ្យមានការប្រឈមខ្ពស់ទៅនឹងការបង្ករោគដ៏គ្រោះថ្នាក់បាន។ ដោយសារមូលហេតុនេះ គេគួរប្រើថ្នាំអង់ទីប៊ីយ៉ូទិកដូចជា ប៉េនីស៊ីលីន( ទំ.៣៥១ ) ឬអំពីស៊ីលីន ( ទំ.៣៥៣ ) ជាបន្ទាន់។

ចំពោះអ្នកដែលមិនបានចាក់វ៉ាក់សាំងបង្ការជំងឺតេតាណូស បើអាចធ្វើទៅបាន គេគួរចាក់ថ្នាំអង់ទីតុកស៊ីនតេតាណូស ( ទំ.៣៨៩ ) ហើយក៏ត្រូវចាក់វ៉ាក់សាំងបង្ការជំងឺតេតាណូសផងដែរ។

បើអាចធ្វើបាន ត្រូវស្វែងរកជំនួយពីគ្រូពេទ្យ!!



## របួសនៅដៃឬជើង ដោយគ្រាប់កាំភ្លើង

- ប្រសិនបើរបួសមានការហូរឈាមច្រើន ឃាត់ឈាម ដូចបានបង្ហាញនៅទំព័រ៨២។
- ប្រសិនបើការហូរឈាមមិនធ្ងន់ធ្ងរ ទុកឲ្យឈាមហូរមួយរយៈខ្លីចុះ។ ការធ្វើយ៉ាងនេះអាចជួយសម្អាតរបួសបាន។
- លាងសម្អាតរបួសនេះជាមួយទឹកឆ្អិនត្រជាក់ល្មម ហើយរុំបង់ដែលស្អាត។ ក្នុងករណីមានរបួសដោយគ្រាប់កាំភ្លើង លាងតែផ្ទៃមុខរបួស( ខាងក្រៅ )បានហើយ។ ជាការល្អប្រសើរ មិនត្រូវញាត់អ្វីចូល ទៅក្នុងរន្ធរបួសនោះឡើយ។
- ឲ្យថ្នាំអង់ទីប៊ីយ៉ូទិក។
- បញ្ជូនអ្នករបួសទៅមន្ទីរពេទ្យដែលនៅជិតបំផុត ដោយរាយការណ៍ឲ្យបានក្បោះក្បាយនូវអ្វីដែលអ្នកបានធ្វើហើយ។



*ការប្រុងប្រយ័ត្ន* ៖

ប្រសិនបើគ្រាប់កាំភ្លើងចូលដល់ឆ្អឹង នោះឆ្អឹងនឹងអាចបាក់បាន។

ការប្រើ ឬដាក់ទម្ងន់ទៅលើអវយវៈ ដែលរបួសនោះ ( ឧទាហរណ៍ ដូចជាឈរ ) អាចបណ្តាលឲ្យបាក់កាន់តែធ្ងន់ធ្ងរថែមទៀត ដូចក្នុងរូបភាពនេះ។

បើសង្ស័យថាមានការបាក់ឆ្អឹង ជាការល្អបំផុតត្រូវអបអវយវៈនោះ ហើយកុំប្រើអវយវៈនោះជាច្រើនអាទិត្យ។



**នៅពេលមានរបួសធ្ងន់ធ្ងរ** លើកផ្នែកដែលមានរបួសឲ្យខ្ពស់ជាងកម្រិតបេះដូង ហើយដាក់អ្នករបួសនោះឲ្យនៅស្ងៀមមួយកន្លែង។




## របួសជ្រៅនៅទ្រូង

របួសទ្រូងអាចបណ្ដាលឲ្យមានគ្រោះថ្នាក់ដ៏ធ្ងន់ធ្ងរបាន។ ត្រូវស្វែងរកជំនួយពីគ្រូពេទ្យជាបន្ទាន់។



- បើរបួសនោះចូលដល់សួត ខ្យល់អាចត្រូវបានបឺតចូលតាមប្រហោងនោះនៅពេលដកដង្ហើម ដូច្នេះ បិទមុខរបួសនោះភ្លាម ដើម្បីកុំឲ្យមានខ្យល់ចូលថែមទៀត។ លាបប្រេងវ៉ាស៊ីលីន ឬប្រេងបន្លែលើដុំកុំប្រេស ឬបង់រុំដែលស្អាត ហើយរុំពីលើប្រហោងនោះឲ្យតឹង ដូចរូបនេះ (ការប្រុងប្រយ័ត្ន ៖ ប្រសិនបើការរុំបង់ដែលតឹងនេះ ធ្វើឲ្យពិបាកដកដង្ហើម នោះត្រូវបន្ធូរវា ឬដោះវាចេញ)។
- ដាក់អ្នករបួសឲ្យស្ថិតក្នុងស្ថានភាពមួយដែលគាត់មានអារម្មណ៍សុខស្រួលបំផុត។
- បើមានរោគសញ្ញាស្ទុក ផ្ដល់ការព្យាបាលដ៏សមស្រប(មើលទំព័រ៧៧)។
- ឲ្យថ្នាំអង់ទីប៊ីយ៉ូទិក និងថ្នាំបំបាត់ការឈឺចាប់។

## របួសក្បាលដោយគ្រាប់កាំភ្លើង

- ដាក់អ្នករបួសក្នុងស្ថានភាពពាក់កណ្ដាលអង្គុយ។
- គ្របមុខរបួសដោយប្រើបង់រុំរបួសដែលស្អាត។
- ឲ្យថ្នាំអង់ទីប៊ីយ៉ូទិក ប៉េនីស៊ីលីន។
- ស្វែងរកជំនួយពីគ្រូពេទ្យ។



# របួសជ្រៅដែលចូលដល់ក្នុងពោះ

គ្រប់របួសដែលចូលដល់ក្នុងពោះឬពោះវៀន គឺជារបួសដែលមានគ្រោះថ្នាក់។ **ស្វែងរកជំនួយពីគ្រូពេទ្យជាបន្ទាន់។** ប៉ុន្តែក្នុងពេលជាមួយគ្នានោះ ៖

បិទមុខរបួសដោយប្រើបង់រុំដែលស្អាត។



ប្រសិនបើពោះវៀនចេញមកខាងក្រៅមុខរបួស គ្របវាដោយប្រើក្រណាត់ស្អាត ដែលផ្សើមដោយទឹកឆ្អិនត្រជាក់ល្មមដែលមានជាតិប្រៃបន្តិច។ មិនត្រូវព្យាយាមរុញពោះវៀននោះចូលទៅក្នុងពោះវិញទេ។ ត្រូវប្រាកដថា ក្រណាត់នោះនៅសើមជានិច្ច។



ប្រសិនបើអ្នករបួសស្ថិតក្នុងសភាពស្លុក លើកជើងគាត់ឲ្យខ្ពស់ជាងក្បាល។

**មិនត្រូវឲ្យអ្នកជំងឺបរិភោគអ្វីតាមមាត់ទេ** ៖ មិនត្រូវឲ្យអាហារ ភេសជ្ជៈ និងសូម្បីតែទឹក - លើកលែងតែក្នុងករណីដែលត្រូវប្រើពេលវេលាលើសពីពីរថ្ងៃក្នុងការបញ្ជូនអ្នករបួសទៅដល់មន្ទីរពេទ្យ។ ក្នុងករណីនេះ សូមបន្តក់ទឹកឲ្យគាត់បន្តិចបន្តួច។







ប្រសិនបើអ្នករបួសកដឹងខ្លួនហើយស្រេកទឹក សូមឲ្យគាត់បឺតក្រណាត់ដែលបានជ្រលក់ក្នុងទឹក។

**មិនត្រូវឲ្យថ្នាំបញ្ចុះលាមកទេ** ៖ ទោះបីជាមានពោះប៉ោងក៏ដោយ ឬអ្នករបួសនោះទល់លាមកជាច្រើនថ្ងៃហើយក៏ដោយ។ បើពោះវៀននោះធ្លាយថ្នាំបញ្ចុះលាមក ឬការលាងពោះវៀន អាចសម្លាប់គាត់បាន។

ចាក់ថ្នាំអង់ទីប៊ីយ៉ូទិក (សូមអានការណែនាំនៅទំព័រខាងក្រោម)។





**កុំរង់ចាំបុគ្គលិកសុខាភិបាល ។ បញ្ជូនអ្នករបួសទៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យដែលនៅជិតបំផុត ជាបន្ទាន់។** គាត់អាចត្រូវការការការវះកាត់។

**ថ្នាំសម្រាប់របួសដែលចូលដល់ពោះវៀន**

(ថ្នាំនេះក៏សម្រាប់ជំងឺរលាកខ្នែងពោះវៀន ឬជំងឺរលាកស្រោមពោះ ដែរ)

**មុនពេលបានទទួលជំនួយពីគ្រូពេទ្យ ធ្វើដូចខាងក្រោម**

ចាក់ថ្នាំអំពីស៊ីលីន (ទំ.៣៥៣) ២ក្រាម (៨អំពូល ២៥០មក្រ) រៀងរាល់ ៤ម៉ោងម្តង។

និងឲ្យថ្នាំមេត្រូនីដាហ្សុល ៥០០មក្រ (ទំ.៣៦៩) រៀងរាល់៦ម៉ោងម្តង។

**បើគ្មានថ្នាំអំពីស៊ីលីន**

ចាក់ប៉េនីស៊ីលីន(គ្រីស្តាលីន ប្រសិនបើអាចរកបាន ទំ.៣៥៣) ៥លានអ៊ុយនីតេភ្លាមៗ បន្ទាប់មក ចាក់ ១លានអ៊ុយនីតេ រៀងរាល់៤ម៉ោងម្តង។ និងឲ្យថ្នាំមេត្រូនីដាហ្សុលថែមទៀត។

ឬឲ្យថ្នាំស៊ីប្រូហ្លុកសាស៊ីន ៥០០មក្រ រៀងរាល់៤ម៉ោងម្តង។ និងឲ្យថ្នាំមេត្រូនីដាហ្សុលថែមទៀត។

បើអ្នកគ្មានថ្នាំអង់ទីប៊ីយ៉ូទិចចាក់ទាំងនេះទេ ឲ្យអំពីស៊ីលីន ឬប៉េនីស៊ីលីន ឬស៊ីប្រូហ្លុកសាស៊ីន តាមមាត់ រួមជាមួយមេត្រូនីដាហ្សុល លេបជាមួយនឹងទឹកបន្តិចបន្តួច។

## ករណីបន្ទាន់នៃបញ្ហាពោះវៀន (ជំងឺពោះស្រួចស្រាល់)

ជំងឺពោះស្រួចស្រាល់ គឺជាឈ្មោះជំងឺមួយដែលបានដាក់សម្រាប់បញ្ហាមួយចំនួនរបស់ពោះវៀន ដែលកើតឡើងភ្លាមៗ និងមានសភាពធ្ងន់ធ្ងរ ហើយអាចត្រូវការការវះកាត់ជាបន្ទាន់ដើម្បីសង្គ្រោះជីវិតរបស់អ្នកជំងឺ។ ឧទាហរណ៍នៃជំងឺនេះ មានដូចជា ជំងឺរលាកខ្នែងពោះវៀន ជំងឺរលាកស្រោមពោះ និងជំងឺស្ទះពោះវៀន (សូមមើលទំព័របន្ទាប់)។ ចំពោះស្ត្រី ជំងឺរលាកអាងត្រគាក (ជាញឹកញាប់ មានធ្លាក់ទឹករំអិលតាមទ្វារមាស មើលទំ.២៤៣) ឬការមានគភ៌ក្រៅស្បូន(នៅក្នុងដៃស្បូន) ក៏អាចបណ្តាលឲ្យជំងឺពោះស្រួចស្រាល់នេះដែរ។ មូលហេតុពិតប្រាកដនៃជំងឺពោះស្រួចស្រាល់អាចមានភាពច្បាស់លាស់ រហូតដល់ពេលគ្រូពេទ្យវះកាត់បានធ្វើការវះបើកពោះ ហើយពិនិត្យមើលនៅខាងក្នុងពោះ។

**ប្រសិនបើមនុស្សម្នាក់មានការឈឺចាប់នៅពោះវៀនយ៉ាងធ្ងន់ធ្ងរ និងបន្តជាប់ ហើយមានក្អួត ប៉ុន្តែគ្មានរាក នោះត្រូវគិតដល់ជំងឺពោះស្រួចស្រាល់។**

**ជំងឺពោះស្រួចស្រាល់**

**នាំអ្នកជំងឺទៅមន្ទីរពេទ្យ ព្រោះគេអាចត្រូវការការវះកាត់**

- ឈឺចាប់ខ្លាំង ជាប់រហូត ហើយកាន់តែធ្ងន់ធ្ងរឡើង
- ទល់លាមក និងក្អួត
- ពោះហើម និងរឹង ហើយអ្នកជំងឺមិនចង់ឲ្យគេប៉ះ
- មានសភាពឈឺធ្ងន់ធ្ងរ

**ជំងឺមិនសូវធ្ងន់ធ្ងរ**

**ប្រហែលអាចព្យាបាលនៅតាមផ្ទះ ឬនៅមណ្ឌលសុខភាព**

- ឈឺបាត់ៗ (ឈឺចុក)
- រាកល្មម ឬរាកធ្ងន់ធ្ងរ
- ជួនកាល មានរោគសញ្ញានៃការបង្ករោគអ្វីមួយ ដែលអាចជាជំងឺផ្តាសាយ ឬការឈឺបំពង់ក
- គាត់ធ្លាប់ឈឺបែបនេះពីមុន
- មានសភាពឈឺល្មមៗ

**ប្រសិនបើអ្នកជំងឺមានរោគសញ្ញានៃជំងឺពោះស្រួចស្រាល់ នាំគាត់ទៅមន្ទីរពេទ្យ ឲ្យបានឆាប់តាមតែអាចធ្វើបាន។**

## ការស្ទះពោះវៀន

ជំងឺពោះស្រួចស្រាល់ អាចបណ្ដាលមកពីមានអ្វីស្ទះនៅផ្នែកណាមួយក្នុងពោះវៀន ដូច្នេះអាហារ និងលាមក មិនអាចឆ្លងកាត់ទៅមុខបានឡើយ។ មូលហេតុជាញឹកញាប់ គឺ ៖

- ការប្រមូលផ្ដុំនៃពពួលព្រូនមូលជាច្រើន (អាស្ការីស ទំ.១៤០)
- ក្មេនពោះវៀនរមួលចូលគ្នានៅក្នុងខ្លួនលូន(ទំ.១៧៧)
- ផ្នែកមួយនៃពោះវៀនរអិលចូលទៅក្នុងពោះវៀនផ្នែកខាងក្រោមវា។

ស្ទើរតែគ្រប់ប្រភេទនៃជំងឺពោះស្រួចស្រាល់ អាចបង្ហាញនូវរោគសញ្ញាខ្លះនៃការស្ទះពោះវៀន។ ព្រោះវាធ្វើឲ្យពោះវៀនដែលខូចមិនអាចធ្វើចលនាបាន។ វាក៏ឈប់ធ្វើចលនា។

រោគសញ្ញានៃការស្ទះពោះវៀន ៖

ក្អួតយ៉ាងខ្លាំង ភ្លាមៗ។ កំអួតអាចព្រួសដល់មួយម៉ែត្រ ឬឆ្ងាយជាងនេះ។ វាអាចមានលាយទឹកប្រមាត់ឬមានក្លិន និងមានលក្ខណៈដូចលាមក។

ឈឺយ៉ាងខ្លាំងជាប់រហូតក្នុងពោះ។ ពោះរបស់កុមារនេះ ឡើងប៉ោង រឹង ហើយឈឺចាប់យ៉ាងខ្លាំង។ វាឈឺកាន់តែខ្លាំងនៅពេលអ្នកប៉ះវា។ កុមារនោះនិងព្យាយាមការពារពោះ និងបត់ជង្គង់របស់វាឡើងលើ។ ពោះរបស់វាគ្មានសំលេងអ្វីទាំងអស់ (បើគេដាក់ត្រចៀកស្ដាប់ជិត គេពុំលឺសូរសំឡេងកូរធម្មតាទេ)។



កុមារតែងតែទល់លាមក (ចលនាពោះវៀនមានតិចតួច ឬគ្មាន)។ បើមានរាក ក៏មានតែតិចតួចប៉ុណ្ណោះ។ ជួនកាលចេញមកតែសំបោរលាយឈាម។

**នាំអ្នកជំងឺទៅមន្ទីរពេទ្យជាបន្ទាន់ តាមដែលអាចធ្វើបាន។** ព្រោះជីវិតរបស់គាត់កំពុងស្ថិតក្នុងសភាពគ្រោះថ្នាក់ ហើយគាត់អាចត្រូវការការវះកាត់ទៀតផង។

## ជំងឺរលាកខ្នែងពោះវៀន និងរលាកស្រោមពោះ

ជាទូទៅ ជំងឺដ៏គ្រោះថ្នាក់ទាំងនេះតែងតែត្រូវការការវះកាត់។ ស្វែងរកជំនួយពីគ្រូពេទ្យឲ្យបានលឿនបំផុត។

ជំងឺរលាកខ្នែងពោះវៀនគឺជាការបង្ករោគនៅខ្នែងពោះវៀន ដែលជាថង់ដូចម្រាមដៃ ជាប់នឹងគល់ពោះវៀនធំ ដែលស្ថិត ផ្នែកខាងក្រោម និងខាងស្ដាំនៃពោះ។ ជួនកាល ខ្នែងពោះវៀនដែលមានការបង្ករោគនោះ អាចបែកធ្លាយ បណ្ដាលឲ្យមានការរលាកស្រោមពោះ។




ជំងឺរលាកស្រោមពោះ គឺជាការបង្ករោគស្រួចស្រាល់ និងធ្ងន់ធ្ងរនៃស្រទាប់ស្រោមពោះ ឬថង់ដែលផ្ទុកពោះវៀន។ វាកើតឡើងនៅពេលដែលខ្នែងពោះវៀន ឬផ្នែកផ្សេងទៀតនៃពោះវៀនធ្លាយ ឬរហែក។

*រោគសញ្ញានៃជំងឺរលាកខ្នែងពោះវៀន*



- រោគសញ្ញាសំខាន់ជាងគេគឺ ការឈឺចាប់ជាប់ នៅក្នុងពោះ ហើយកាន់តែឈឺខ្លាំងឡើងៗ។
- វាច្រើនចាប់ផ្តើមឈឺនៅជុំវិញផ្ចិត ប៉ុន្តែវារាលដាលយ៉ាងរហ័សទៅផ្នែកខាងក្រោម និងខាងស្តាំ។
- អ្នកជំងឺមិនឃ្លានអាហារ ក្អួត ទល់លាមក និងមានគ្រុនក្តៅបន្តិចបន្តួច។

**ការពិនិត្យរកមើលជំងឺរលាកខ្នែងពោះវៀន និងជំងឺរលាកស្រោមពោះ**



ឲ្យអ្នកជំងឺក្អក ហើយមើលថាតើ ការក្អកនេះធ្វើឲ្យគាត់មានការឈឺចាប់កាន់តែខ្លាំង នៅក្នុងពោះ ឬទេ ។

ឬសង្កត់យឺតៗ ប៉ុន្តែខ្លាំង នៅពោះផ្នែកខាងលើបន្តិចនៃក្រលៀនខាងឆ្វេង យឺតៗ រហូតដល់មានការឈឺចាប់បន្តិចបន្តួច។

បន្ទាប់មក ដកដៃចេញវិញយ៉ាងលឿន។



បើមានការឈឺចាប់យ៉ាងខ្លាំង កើតឡើងនៅពេលដែលដកដៃចេញ នោះប្រហែលជាជំងឺរលាកខ្នែងពោះវៀន ឬជាជំងឺរលាកស្រោមពោះហើយ។

បើគ្មានការឈឺចាប់នៅខាងលើក្រលៀនខាងឆ្វេងទេ សាកល្បងធ្វើរបៀបនេះនៅខាងលើក្រលៀនខាងស្តាំម្តង។

**ក្នុងករណីដែលអ្នកគិតថា អ្នកជំងឺអាចមានជំងឺរលាកខ្នែងពោះវៀនឬរលាកស្រោមពោះ**

- **ស្វែងរកជំនួយពីគ្រូពេទ្យជាបន្ទាន់** ៖ បើអាច នាំអ្នកជំងឺទៅកន្លែងដែលមានការវះកាត់។
- **មិនត្រូវឲ្យអ្វីដល់អ្នកជំងឺតាមមាត់ទេ** ៖ មិនត្រូវឲ្យទឹកបញ្ចុះលាងពោះវៀនទេ។ លើកលែងតែករណីដែលអ្នកជំងឺចាប់ផ្តើមបង្ហាញរោគសញ្ញាខ្សោះជាតិទឹក ឲ្យគាត់ក្រេបទឹក ឬទឹក (ទំ.១៥២) ដែលមានអំបិល និងស្ករ ដោយមិនត្រូវបន្ថែមអ្វីទៀតឡើយ។



- អ្នកជំងឺគួរសម្រាកយ៉ាងស្ងៀមស្ងាត់ក្នុងស្ថានភាពពាក់កណ្តាលអង្គុយ។

**ចំណាំ** ៖ នៅពេលដែលជំងឺរលាកស្រោមពោះវៀនមានសភាពធ្ងន់ធ្ងរ ពោះឡើងរឹងដូចបន្ទះក្តារ ហើយអ្នកជំងឺមានអារម្មណ៍ឈឺចាប់យ៉ាងខ្លាំងនៅពេលប៉ះពោះរបស់គាត់ ទោះបីជាប៉ះយ៉ាងស្រាលក៏ដោយ។ ជីវិតគាត់ស្ថិតក្នុងសភាពគ្រោះថ្នាក់ ដូច្នេះនាំគាត់ទៅមន្ទីរពេទ្យជាបន្ទាន់។ ហើយនៅតាមផ្លូវ ឲ្យថ្នាំដូចដែលបានរៀបរាប់នៅទំ.៩៣។

# រលាក

*ការបង្ការ*

ការរលាកជាច្រើន អាចបង្ការបាន។ យកចិត្តទុកដាក់ពិសេសចំពោះកុមារ ៖

- កុំឲ្យកុមារនៅក្បែរភ្លើង។
- ទុកចង្កៀង ឬឈើគូសឲ្យឆ្ងាយពីដៃរបស់វា។
- បង្វិលដៃឆ្នាំងនៅលើចង្ក្រានកុំឲ្យវាលូកដល់។



## ការរលាកស្រាលដែលគ្មានពងទឹក (កម្រិតទី១)

ដើម្បីជួយសម្រាលការឈឺចាប់និងបន្ថយការខូចខាតដែលបណ្តាលមកពីការរលាកស្រាល ត្រាំផ្ទៃរលាកទៅក្នុងទឹកត្រជាក់ **ភ្លាម**។ គេមិនត្រូវការការព្យាបាលផ្សេងទៀតទេ។ គេអាចលេបអាស្ពីរីនដើម្បីបន្ថយការឈឺចាប់។

## ការរលាកដែលមានពងទឹក (កម្រិតទី២)

កុំបំបែកពងទឹកនោះឲ្យសោះ។ បើពងទឹកនោះបែក លាងវាដោយថ្នមៗជាមួយសាប៊ូ និងទឹកឆ្អិនដែលត្រជាក់។ យកវ៉ាស៊ីលីនបន្តិចទៅរម្ងាប់មេរោគដោយកម្តៅវារហូតដល់វាពុះ រួចប៉ាតលើកុំប្រេសស្តេរីល។ បន្ទាប់មក ដាក់កុំប្រេសនោះទៅដាក់លើផ្ទៃរលាក។ បើគ្មានវ៉ាស៊ីលីនទេ ទុកកន្លែងរលាកឲ្យចំហរ។ កុំលាបខ្លាញ់ ឬប៊ឺឲ្យសោះ។

| **ការសំខាន់គឺត្រូវរក្សាកន្លែងរលាកឲ្យបានស្អាត។ ការពារវាពីភាពកខ្វក់ ធូលី និងសត្វរុយ។** |
|---|

បើមានរោគសញ្ញានៃការបង្ករោគ ដូចជាមានខ្ទុះ ក្លិនស្អុយ គ្រុនក្តៅ ឬហើមកូនកណ្តុរ បិទរបួសនោះដោយកុំប្រេសដែលជ្រមើមដោយទឹកអំបិលក្តៅឧណ្ហៗ(អំបិលមួយស្លាបព្រាកាហ្វេលាយទឹកមួយលីត្រ) ៣ដងក្នុងមួយថ្ងៃ។ ត្រូវដាំទឹកនិងស្ងោរកុំប្រេស មុននឹងប្រើប្រាស់វា។ យកស្បែកនិងសាច់ដែលងាប់ចេញដោយប្រុងប្រយ័ត្ន។ អ្នកអាចលាបក្រមួនថ្នាំអង់ទីប៊ីយ៉ូទិច ដូចជា ណេអូស្ពរីន (Neosporin ទំ.៣៧១)។ ក្នុងករណីធ្ងន់ គិតទៅដល់ការប្រើប៉េនីស៊ីលីន ឬអំពីស៊ីលីន។

## រលាកជ្រៅ (កម្រិតទី៣)

ដែលបំផ្លាញស្បែកនិងរលាកជ្រៅដល់សាច់ដុំ ឬខ្លោចសាច់ គឺជាការរលាកធ្ងន់ធ្ងរ ដូចការរលាកយ៉ាងធំនៅលើរាងកាយដែរ។ នាំអ្នកជំងឺទៅមន្ទីរពេទ្យជាបន្ទាន់។ ក្នុងពេលជាមួយគ្នានោះ គ្របកន្លែង ដែលរលាកដោយក្រណាត់ ឬកន្សែងដែលស្អាត។

បើមិនអាចស្វែងរកជំនួយពីគ្រូពេទ្យបាន ព្យាបាលដូចបានរៀបរាប់ខាងលើ។ បើអ្នកគ្មានវ៉ាស៊ីលីនទេ ទុកកន្លែងរលាកឲ្យនៅចំហ ដោយរុំវាធូរៗជាមួយក្រណាត់ទុនៗ ដើម្បីការពារកុំឲ្យធូលីចូល ឬមានរុយរោម។ ក្រណាត់នោះត្រូវតែស្អាតជាទីបំផុត ហើយផ្លាស់ប្តូរវានៅរាល់ពេលដែលវាមានប្រឡាក់ទឹកឬឈាម ដែលចេញពីរបួសរលាកនោះ។ ឲ្យថ្នាំប៉េនីស៊ីលីន។

**មិនត្រូវលាបប្រេង ស្បែក កាហ្វេ ស្មៅ ឬលាមក នៅផ្ទៃរលាកនោះទេ។**

ការ**លាបទឹកឃ្មុំ** នៅមុខរបួសរលាក អាចជួយបង្ការនិងគ្រប់គ្រងការបង្ករោគ និងជំរុញឲ្យឆាប់ជាសះស្បើយ។ លាងសម្អាតទឹកឃ្មុំចាស់ចេញដោយថ្នម ហើយលាបទឹកឃ្មុំថ្មីទៀត យ៉ាងហោចពីរដងក្នុងមួយថ្ងៃ។

## ការប្រុងប្រយ័ត្នពិសេសចំពោះការរលាកធ្ងន់ធ្ងរ

អ្នកដែលមានការរលាកយ៉ាងធ្ងន់ធ្ងរ អាចធ្លាក់ក្នុងសភាពស្ពុកបានយ៉ាងងាយ ( ទំ.៧៧ ) ដោយសារការឈឺចាប់ ការភ័យខ្លាច និងការបាត់បង់ជាតិទឹកក្នុងខ្លួន ដែលបណ្តាលមកពីការជ្រាបទឹកចេញពីមុខរបួសរលាក។

ត្រូវធ្វើឲ្យអ្នករលាកមានផាសុខភាពនិងមានការទុកចិត្ត។ ឲ្យអាស្ពីរីន ដើម្បីបំបាត់ការឈឺចាប់ និងកូដេអ៊ីន ( codeine ) បើអាចរកបាន។ ការលាងកន្លែងរលាកដោយប្រើទឹកអំបិលប្រៃល្មម ក៏អាចជួយបំបាត់ការឈឺចាប់ដែរ។ ដាក់អំបិលមួយស្លាបព្រាកាហ្វេក្នុងទឹកឆ្អិនមួយលីត្រ។

ឲ្យអ្នករលាកពិសារទឹកឲ្យបានច្រើន។ បើកន្លែងរលាកមានផ្ទៃធំ( ធំជាងទំហំដៃពីរដង ) លាយទឹកដូចខាងក្រោមនេះ




អ្នករលាកត្រូវផឹកទឹកនេះឲ្យបានញឹកញាប់តាមដែលអាចធ្វើបាន ជាពិសេសត្រូវផឹករហូតដល់គាត់នោមជាច្រើនដង។ គាត់ត្រូវព្យាយាមផឹកទឹកឲ្យបាន៤លីត្រក្នុងមួយថ្ងៃ ជារៀងរាល់ថ្ងៃសម្រាប់ការរលាកធំ និង១២លីត្រក្នុងមួយថ្ងៃសម្រាប់ការរលាកធំយ៉ាងខ្លាំង។

វាជាការសំខាន់ណាស់ដែលអ្នកដែលមានការរលាកយ៉ាងធ្ងន់ធ្ងរ ត្រូវបរិភោគអាហារដែលសំបូរជាតិប្រូតេអ៊ីន ( ទំ.១១០ )។ មិនត្រូវតមអាហារទេ។

## ការរលាកនៅជុំវិញសន្លាក់

កាលណាមាននណារម្នាក់មានការរលាកធ្ងន់ធ្ងរ នៅចន្លោះម្រាមដៃ ក្លៀក ឬនៅសន្លាក់ផ្សេងទៀត យកកុំប្រេសលាប វ៉ាស៊ីលីនដាក់នៅចន្លោះផ្ទៃរលាក ដើម្បីការពារកុំឲ្យដុះសាច់ជាប់គ្នា នៅពេលដែលផ្សះ។ ម្យ៉ាងទៀត ម្រាមដៃ ដៃ និងជើង ដែលមានការរលាក ត្រូវពន្លារឲ្យត្រង់ទាំងស្រុង ជាច្រើនដងក្នុងមួយថ្ងៃនៅពេលដែលវាកំពុងមានការជាផ្សះ។ ការធ្វើរបៀបនេះអាចមានការឈឺ តែអាចជួយបង្ការការរឹងសន្លាក់។ នៅពេលដៃដែលរលាកកំពុងមានការជាសះគួរដាក់ម្រាមដៃក្នុងស្ថានភាពបត់បន្តិច។



# ការបាក់ឆ្អឹង

នៅពេលដែលមានការឆ្អឹងបាក់ ការសំខាន់បំផុតដែលត្រូវធ្វើគឺ **រក្សាឆ្អឹងនោះឲ្យស្ថិតក្នុងស្ថានភាពដែលមានលំនឹង។** ការធ្វើរបៀបនេះ អាចជួយបង្ការការខូចខាតបន្ថែមទៀត និងជួយឲ្យមានការជាសះស្បើយឡើងវិញ។

មុននឹងព្យាយាមរំកិល ឬលើកអ្នកបាក់ឆ្អឹង ទប់ឆ្អឹងនោះកុំឲ្យមានចលនាដោយប្រើរណប បន្ទះឈើ ឬក្រដាសក្រាស់រឹង។ ក្រោយមក គេអាចរុំប្លាតនៅលើអវយវៈនោះ នៅមណ្ឌលសុខភាព ឬ អ្នកអាចរណបតាមទំនៀមទម្លាប់នៅក្នុងស្រុករបស់អ្នក( ចូរអានទំ.១៤ )។

**ការទាញតម្រង់ឆ្អឹងដែលបាក់** ៖ បើឆ្អឹងដែលបាក់នោះហាក់ដូចជាស្ថិតនៅត្រូវកន្លែងល្អ ឬខុសបន្តិចបន្តួច នោះគេមិនគួរប៉ះពាល់វាទេ ព្រោះវាអាចធ្វើឲ្យមានផលអាក្រក់ច្រើនជាងផលល្អ។

បើចុងឆ្អឹងបាក់នោះស្ថិតនៅឆ្ងាយពីគ្នា ហើយវាគឺជាការបាក់ថ្មីៗ នោះអ្នកអាចសាកល្បងតម្រង់វាមុនពេលរុំប្លាត។ ការទាញតម្រង់ឆ្អឹងនេះ បើកាន់តែឆាប់ធ្វើ កាន់តែងាយធ្វើ។ មុនពេលទាញតម្រង់ឆ្អឹងនេះ ប្រសិនបើអាច ចាក់ថ្នាំឬ ឲ្យថ្នាំឌីយ៉ាសេប៉ាម( Diazepam ) ដើម្បីធ្វើឲ្យសាច់ដុំរលា និងជួយបំបាត់ការឈឺចាប់ផង( ទំ.៣៩០ )។ ឬឲ្យកូដេអ៊ីន ( Codeine ទំ.៣៨៤ )។

### របៀបទាញតម្រង់ឆ្អឹងកដៃដែលបាក់







***ការប្រយ័ត្ន*** **៖ ការព្យាយាមទាញតម្រង់ឆ្អឹងនេះ អាចធ្វើឲ្យមានការខូចខាតជាច្រើន។ ជាការល្អ ការទាញតម្រង់ឆ្អឹង គួរធ្វើឡើងដោយមានការជួយពីអ្នកដែលមានបទពិសោធន៍។ មិនត្រូវទាញកន្ត្រាក់ ឬទាញបង្ខំទេ។**

### តើឆ្អឹងបាក់អាចជាសះស្បើយក្នុងរយៈពេលប៉ុន្មាន ?

កាលណាឆ្អឹងបាក់កាន់តែខ្លាំង ឬចំពោះមនុស្សកាន់តែចាស់ រយៈពេលនៃការជាសះស្បើយរបស់ឆ្អឹងនឹងកាន់តែយូរ។ ឆ្អឹងក្មេងអាចតជាប់វិញបានយ៉ាងឆាប់រហ័ស។ ការបាក់ឆ្អឹងរបស់មនុស្សចាស់ ជួនកាលមិនអាចជាប់វិញទេ។ ដៃដែលបាក់ ត្រូវដាក់ប្លាតអបក្នុងរយៈពេលប្រហែលមួយខែ ហើយមិនត្រូវដាក់ទម្ងន់ទៅលើដៃនោះក្នុងរយៈពេលមួយខែបន្ទាប់។ ឆ្អឹងជើងដែលបាក់ត្រូវដាក់ប្លាតអបរយៈពេលប្រហែលពីរខែ។

### ការបាក់ឆ្អឹងភ្លៅ ឬឆ្អឹងត្រគាក

ជាទូទៅ ការបាក់ឆ្អឹងភ្លៅ ឬឆ្អឹងត្រគាក តែងតែត្រូវការការយកចិត្តទុកដាក់ពិសេស។ ជាការល្អបំផុត គឺត្រូវអបខ្លួនទាំងមូល ដូចក្នុងរូបភាពនេះ។



ហើយនាំអ្នករបួសទៅមន្ទីរពេទ្យជាបន្ទាន់។

### ការបាក់ឆ្អឹងក និងឆ្អឹងខ្នង

បើមាននរណាម្នាក់មានបាក់ឆ្អឹងខ្នង ឬឆ្អឹងក **ត្រូវប្រុងប្រយ័ត្នជាទីបំផុតនៅពេលលើកគាត់។** ត្រូវព្យាយាមកុំផ្លាស់ប្តូរស្ថានភាពរបស់គាត់។ បើអាចធ្វើបាន អញ្ជើញបុគ្គលិកសុខាភិបាលមក មុននឹងលើកគាត់។ បើអ្នកត្រូវលើកគាត់ជាចាំបាច់ ត្រូវធ្វើដោយគ្មានការបត់ខ្នង ឬករបស់គាត់។ សម្រាប់សេចក្តីណែនាំអំពីការលើកអ្នករបួស សូមអានទំព័របន្ទាប់។

### ការបាក់ឆ្អឹងជំនីរ

ការបាក់ជំនីរបណ្តាលឲ្យមានការឈឺចាប់យ៉ាងខ្លាំង ប៉ុន្តែភាគច្រើន វាតែងតែជាដោយខ្លួនឯង។ ជាការប្រសើរមិនបាច់ដាក់ប្លាតអបទ្រូងនោះទេ។ ការព្យាបាលដែលល្អបំផុត គឺការប្រើថ្នាំអាស្ពីរីន និងការសម្រាក។ ដើម្បីរក្សាសួតឲ្យមានសុខភាពល្អ ដកដង្ហើមវែងៗ ៤ទៅ ៥ដងជាប់ៗគ្នា រៀងរាល់ពីរម៉ោង។ ត្រូវធ្វើរបៀបនេះរាល់ថ្ងៃ រហូតដល់អាចដកដង្ហើមបានដូចធម្មតា។ នៅពេលដំបូង ការដកដង្ហើមនឹងធ្វើឲ្យមានការឈឺចាប់យ៉ាងខ្លាំង។ វាអាចប្រើរយៈពេលជាច្រើនខែ មុននឹងការឈឺចាប់បាត់ទៅវិញទាំងស្រុង។

ជាញឹកញាប់ ឆ្អឹងជំនីរដែលបាក់មិនទំលុះដល់សួតទេ។ ប៉ុន្តែ បើឆ្អឹងជំនីរនោះបាក់ធ្លាយស្បែក ឬបើអ្នករបួសនោះក្អកមានឈាម ឬពិបាកដកដង្ហើម ប្រើថ្នាំអង់ទីប៊ីយ៉ូទិក (ប៉េនីស៊ីលីន ឬអំពីស៊ីលីន)។ ស្វែងរកជំនួយពីគ្រូពេទ្យជាបន្ទាន់។

### ការបាក់ឆ្អឹងដែលមានធ្លាយស្បែក(ការបាក់ចំហ)



ដោយសារករណីបាក់ឆ្អឹងរបៀបនេះ មានគ្រោះថ្នាក់ដ៏ធ្ងន់ធ្ងរនៃការបង្ករោគ ការស្វែងរកជំនួយពីបុគ្គលិកសុខាភិបាល ឬវេជ្ជបណ្ឌិតដើម្បីព្យាបាលរបួសនេះ គឺជាការប្រសើរបំផុត។ សម្អាតរបួស និងឆ្អឹងដែលលានចេញដោយថ្នមៗនិងដោយ ហ្មត់ចត់ ជាមួយទឹកឆ្អិន ហើយគ្របមុខរបួសដោយក្រណាត់ស្អាត។ **មិនត្រូវរុញឆ្អឹងចូលទៅក្នុងវិញ រហូតដល់ពេលរបួសនិងឆ្អឹងនោះស្អាតទាំងស្រុង។**

អបអវយវៈនោះដើម្បីបង្ការការមានរបួសបន្ថែមទៀត។

បើឆ្អឹងបានមុតធ្លាយស្បែក ប្រើថ្នាំអង់ទីប៊ីយ៉ូទិកភ្លាមដើម្បីបង្ការការបង្ករោគ ៖ ប្រើថ្នាំប៉េនីស៊ីលីន អំពីស៊ីលីន ឬតេត្រាស៊ីគ្លីន(ទំ.៣៥១ ៣៥៣ និង៣៥៥)។

***ការប្រុងប្រយ័ត្ន*** **៖ មិនត្រូវច្របាច់ ឬម៉ាសាអវយវៈដែលបាក់ ឬអវយវៈដែលសង្ស័យថាបាក់នោះទេ។**

# របៀបលើក ដាក់អ្នកមានរបួសធ្ងន់ធ្ងរ



ត្រូវលើកអ្នករបួសដោយប្រុងប្រយ័ត្នបំផុត ដោយគ្មានការបត់ខ្លួនរបស់គាត់ទេ។ ត្រូវយកចិត្តទុកដាក់ពិសេស ចំពោះក្បាលនិងក គឺមិនត្រូវធ្វើឲ្យបត់ឡើយ។



មានមនុស្សម្នាក់ទៀតដាក់ស្នែងឲ្យចំកន្លែង។



ដោយមានការជួយពីមនុស្សទាំងអស់គ្នា ដាក់អ្នករបួសនៅលើគ្រែស្នែង ដោយប្រុងប្រយ័ត្ន។





បើឆ្អឹងកមានរបួស ឬបាក់ ដាក់បាវដីខ្សាច់ ឬញាត់ក្រណាត់ឲ្យណែន ដាក់នៅសងខាងក្បាល ដើម្បីទប់កុំឲ្យងាកបាន។

នៅពេលសែងអ្នកជំងឺ ត្រូវធ្វើឲ្យជើងអ្នកជំងឺនៅខ្ពស់ជានិច្ច ទោះជាសែងឡើងទួលក៏ដោយ។

# ការភ្លាត់ឆ្អឹង ( សន្លាក់ឆ្អឹងភ្លាត់ចេញពីគ្នា )

ចំណុចសំខាន់ៗបីក្នុងការព្យាបាល ៖

- ព្យាយាមដាក់ឆ្អឹងឲ្យចូលកន្លែងដើមវិញ។ **កាន់តែឆាប់ធ្វើ កាន់តែប្រសើរ។**
- ត្រូវទប់ឲ្យនៅកន្លែងត្រឹមត្រូវរបស់វា ដោយរុំបង់យ៉ាងមាំ ដើម្បីកុំឲ្យវាភ្លាត់វិញទៀត(ប្រហែលជាមួយខែ)។
- ជៀសវាងការប្រើអវយវៈនោះខ្លាំង ក្នុងរយៈពេលយូរល្មមដែលអាចឲ្យសន្លាក់ឆ្អឹងនោះជាសះស្បើយទាំងស្រុង (រយៈពេល២ ឬ៣ខែ)។

## របៀបទាញតម្រង់សន្លាក់ឆ្អឹងស្មាដែលភ្លាត់

ដាក់អ្នករបួសឲ្យដេកផ្កាប់មុខលើតុមួយ ឬលើផ្ទៃរឹងរាបស្មើផ្សេងទៀត ដោយឲ្យដាក់ដៃសំយុងចុះមកក្រោម។ ទាញដៃចុះមកក្រោម ដោយប្រើកម្លាំងខ្លាំងថេរ រយៈពេល១៥ ទៅ២០នាទី។ បន្ទាប់មក លែងវិញដោយថ្នមៗ។ ស្មានឹងត្រឡប់ទៅកន្លែងដើមវិញ។



ឬចងព្យួរវត្ថុអ្វីមួយនៅដៃ ដែលមានទម្ងន់ប្រហែល៥ទៅ១០គីឡូក្រាម ( ចាប់ផ្តើមពី ៥គីឡូក្រាម តែមិនត្រូវលើស ពី១០គីឡូក្រាមទេ ) ហើយព្យួរវារយៈពេល១៥ទៅ២០នាទី។



បន្ទាប់ពីស្មាបានចូលកន្លែងដើមវិញហើយ រុំដៃនោះឲ្យមាំ ជាប់ជាមួយនឹងខ្លួន។ ទុកបង់រុំនោះរយៈពេលពីមួយសប្តាហ៍ទៅមួយខែ។ ដើម្បីការពារសន្លាក់ស្មាកុំឲ្យជាប់គាំង ស្រាយបង់រុំនោះរយៈពេលពីរបីនាទី ៣ដងក្នុង១ថ្ងៃ ដោយទម្លាក់ដៃឲ្យស្របចំហៀងខ្លួន ហើយបង្វិលដៃចុះឡើងបន្តិចបន្តួចដោយថ្នមៗ។ មិនត្រូវប្រើដៃនោះលើករបស់ធ្ងន់ៗ រយៈពេលមួយខែ ដើម្បីកុំឲ្យសន្លាក់ស្មានោះភ្លាត់ឡើងវិញទៀត។

ក្នុងករណីដែលអ្នកពុំអាចទាញសន្លាក់អវយវៈភ្លាត់ឲ្យចូលកន្លែងដើមវិញបាន ស្វែងរកជំនួយពីគ្រូពេទ្យជាបន្ទាន់។ បើទុកកាន់តែយូរ កាន់តែពិបាកកែតម្រូវ។

# ការរមួល និងការគ្រេច( ការខ្ទាំ ឬការរហែកត្រង់សន្លាក់ដែលរមួល )

ជាញឹកញាប់ គេមិនអាចដឹងថាតើដៃឬជើងមានខ្ទាំ គ្រេច ឬបាក់ទេ។ ការថតកាំរស្មីអ៊ិច អាចជួយយើងបាន។

ប៉ុន្តែ ជាទូទៅការបាក់និងគ្រេចត្រូវបានព្យាបាលស្ទើរតែដូចគ្នា។ រក្សាសន្លាក់មិនឲ្យមានចលនា។ រុំវាដោយអ្វីដែលអាចទប់បានយ៉ាងមាំ។ ការគ្រេចធ្ងន់ធ្ងរ ត្រូវការរយៈពេលយ៉ាងហោច ពី៣ទៅ៤អាទិត្យទើបជា។ ការបាក់ឆ្អឹងត្រូវការរយៈពេលយូរជាងនេះ។

ដើម្បីសម្រាលការហើម និងការឈឺចាប់ លើកកន្លែងគ្រេចនោះឲ្យខ្ពស់។ ក្នុងកំឡុងពេលមួយឬពីរថ្ងៃដំបូង ស្អំទឹកកក ឬទឹកត្រជាក់ ដោយប្រើក្រណាត់សើម ឬប្រើថង់ខ្ចប់ទឹកកកដាក់លើសន្លាក់ដែលហើម ក្នុងរយៈពេលពី២០ទៅ៣០នាទី រៀងរាល់មួយម៉ោងម្តង។ ការធ្វើរបៀបនេះ អាចជួយបន្ធូរការហើម និងឈឺចាប់។ បន្ទាប់ពី២៤ទៅ៤៨ម៉ោង(នៅពេលដែលការហើមនោះលែងធ្ងន់ធ្ងរតទៅទៀត) ត្រាំកន្លែងគ្រេចនោះក្នុងទឹកក្តៅល្មម ជាច្រើនដងក្នុងមួយថ្ងៃ។



*ថ្ងៃទីមួយ ត្រាំសន្លាក់ដែលគ្រេចក្នុងទឹកត្រជាក់*


*បន្ទាប់ពីមួយឬពីរថ្ងៃ ត្រាំក្នុងទឹកក្តៅឧណ្ហៗវិញ*

អ្នកអាចទុកសន្លាក់ដែលរមួលឲ្យស្ថិតនៅក្នុងទីតាំងដែលត្រឹមត្រូវរបស់វា ដើម្បីឲ្យវាជាសះស្បើយ ដោយប្រើរណបដែលធ្វើនៅតាមផ្ទះ ឬដោយរុំបង់យឺត។



ការរុំប្រអប់ជើង និងកជើងដោយបង់យឺតក៏អាចជួយការពារ ឬកាត់បន្ថយការហើមដែរ។ ចាប់ផ្តើមរុំពីម្រាមជើងឡើងលើ ដូចមានបង្ហាញក្នុងរូប។ ប៉ុន្តែ ប្រយ័ត្ន មិនត្រូវរុំឲ្យតឹងពេកទេ ហើយលាវាចេញនៅរៀងរាល់មួយឬពីរម៉ោង។ ឲ្យថ្នាំអាស្ពីរីនផង។

បើការឈឺចាប់និងការហើមមិនទាន់ថយចុះទេបន្ទាប់ពី ៤៨ម៉ោង ស្វែងរកជំនួយពីគ្រូពេទ្យជាបន្ទាន់។

***ការប្រុងប្រយ័ត្ន*** **៖ កុំច្របាច់ ឬម៉ាសាកន្លែងឆ្អឹងគ្រេចឬបាក់ឲ្យសោះ។ វាមិនបានផ្តល់ផលល្អអ្វីទេ ហើយអាចធ្វើឲ្យកាន់តែគ្រោះថ្នាក់ថែមទៀតផង។**

បើប្រអប់ជើងហាក់ដូចជាខ្សោយឬទុន ឬបើអ្នកជំងឺមានការពិបាកក្នុងការកម្រើកម្រាមជើង រកជំនួយពីគ្រូពេទ្យ។ អ្នកជំងឺនោះអាចត្រូវការការវះកាត់។

# ការពុល

មានកុមារជាច្រើនស្លាប់ដោយការលេបវត្ថុដែលមានជាតិពុល។ ដើម្បីការពារកូនរបស់អ្នក អនុវត្តវិធានការប្រុងប្រយ័ត្ន ដូចខាងក្រោម ៖

**ទុកវត្ថុដែលមានជាតិពុលទាំងអស់ឲ្យផុតពីដៃកុមារ**



**កុំទុកប្រេងកាត ប្រេងសាំង ឬសារធាតុពុលផ្សេងៗទៀត នៅក្នុងដបកូកាកូឡា ឬក្នុងដបភេសជ្ជៈ ព្រោះកុមារអាចផឹកវា។**



**សារធាតុពុលមួយចំនួនដែលត្រូវប្រុងប្រយ័ត្ន**

- ថ្នាំបំពុលកណ្តុរ
- ឡាំងដាន និងថ្នាំសម្លាប់សត្វល្អិតដេដេតេ
- ថ្នាំពេទ្យ គ្រប់ប្រភេទ បើប្រើច្រើនពិសេសថ្នាំគ្រាប់ជាតិដែក។
- ទឹកថ្នាំអ៊ីយ៉ូត
- ទឹកលាងសម្អាត
- បារី
- ថ្នាំលាបឈើ
- ស្លឹក គ្រាប់ធញ្ញជាតិ ឬផ្សិតផ្សេងៗដែលពុល
- ឈើគូស
- ប្រេងកាត ប្រេងសាំង កំបោរ
- ទឹកក្បុង ឬជាតិអាស៊ីត
- អំបិល (បើគេឲ្យទៅទារក និងកុមារតូចៗច្រើនពេក)
- អាហារដែលខូច(ទំ.១៣៦)។

*ការព្យាបាល*

បើអ្នកសង្ស័យថាមានការពុល ធ្វើដូចខាងក្រោម **ជាបន្ទាន់** ៖

- ប្រសិនបើកុមារនៅដឹងខ្លួន ធ្វើឲ្យគាត់ក្អួតចេញមក ដោយលូកដៃរបស់អ្នកចូលក្នុងបំពង់កររបស់គាត់ ឬឲ្យគាត់ផឹកអ៊ីប៉េកា មួយស្លាព្រាកាហ្វេ(ទំ.៣៨៩) បន្ទាប់មកឲ្យគាត់ផឹកទឹកមួយកែវ។ ឬឲ្យគាត់ផឹកទឹកដែលមានជាតិសាប៊ូបន្តិចបន្តួច ឬអំបិល (អំបិល៦ស្លាបព្រាកាហ្វេជាមួយទឹកមួយកែវ)។
- ប្រសិនបើអ្នកមាន ឲ្យគាត់ផឹកទឹកថ្នាំកាបូន(ទំ.៣៨៩)មួយពែង ឬថ្នាំម្សៅកាបូនមួយស្លាព្រាបាយលាយជាមួយទឹកមួយពែង (សម្រាប់មនុស្សធំ ឲ្យពីរកែវ)។

*ការប្រុងប្រយ័ត្ន ៖* មិនត្រូវធ្វើឲ្យអ្នកជំងឺក្អួតទេ ប្រសិនបើគាត់បានផឹកប្រេងកាត ប្រេងសាំង ឬអាស៊ីតខ្លាំង ឬវត្ថុដែលមានជាតិកាត់ "សាប៊ូ ទឹកក្បុង" ឬប្រសិនបើគាត់មិនដឹងខ្លួន។ បើគាត់នៅដឹងខ្លួន ឲ្យគាត់ផឹកទឹកឬទឹកដោះគោឲ្យបានច្រើន ដើម្បីពង្រាវជាតិពុល (សម្រាប់កុមារ ត្រូវឲ្យផឹក១កែវនៅរៀងរាល់១៥នាទី)។

ដណ្តប់ភួយឲ្យអ្នកជំងឺប្រសិនបើគាត់មានអារម្មណ៍រងារ ប៉ុន្តែត្រូវចៀសវាងការក្តៅពេក។ **ប្រសិនបើពុលធ្ងន់ធ្ងរ ត្រូវស្វែងរកជំនួយពីគ្រូពេទ្យជាបន្ទាន់។**

# ពស់ចឹក



ស្ថិតក្នុងតំបន់អាស៊ីភាគអាគ្នេយ៍។ ពោរពេញដោយជាតិពិស និងអាចសម្លាប់អាយុជីវិតបានយ៉ាងងាយ។ ឈ្មោះវិទ្យាសាស្ត្រនៃពស់ពិសនេះគឺ ខាឡូសេឡាស្មា រ៉ូដូស្តូម៉ា (Calloselasma rhodostoma)។

នៅពេលដែលមាននរណាម្នាក់ត្រូវពស់ចឹក ត្រូវព្យាយាមស្វែងយល់ថា តើពស់នោះជាពស់ពិស ឬជាពស់គ្មានពិស? ស្នាមខាំរបស់វាមានសភាពខុសពីគ្នា ៖

*ពស់ពិស*



*ស្នាមចង្កូម*

*ការចឹករបស់ពស់ពិសភាគច្រើនបានបន្សល់ទុកស្នាមចង្កូមពីរ ហើយជួនកាលមានបន្សល់ស្នាមធ្មេញ តូចៗផ្សេងទៀត។*

*ពស់គ្មានពិស*



*ការចឹករបស់ពស់គ្មានពិសបន្សល់ទុកតែស្នាមធ្មេញពីរជួរ ប៉ុន្តែគ្មានស្នាមចង្កូមទេ។*

គេច្រើនតែជឿថា ពស់មួយចំនួនដែលមិនបង្កគ្រោះថ្នាក់ក៏មានពិសដែរ ។ ព្យាយាមស្វែងយល់ពីប្រភេទពស់ដែលមានពិសពិតប្រាកដ និងពស់ដែលគ្មានពិស នៅក្នុងតំបន់អ្នក។ ផ្ទុយពីមតិជាច្រើនដែលយល់ថាពស់ថ្លាន់គ្មានពិស។ សូមកុំសម្លាប់ពស់គ្មានពិស ពីព្រោះវាមិនផ្តល់គ្រោះថ្នាក់អ្វីឡើយ។ ផ្ទុយទៅវិញ វាសម្លាប់កណ្តុរ និងសត្វចង្រៃផ្សេងៗ ដែលធ្វើឲ្យមានការខូចខាតជាច្រើន។ ពស់ថ្លាន់ខ្លះថែមទាំងសម្លាប់ពស់មានពិសទៀតផង។

*វិធីព្យាបាលសម្រាប់ពស់ពិសចឹក*

១. **នៅឲ្យស្ងៀម ៖ មិនត្រូវធ្វើចលនាទៅលើផ្នែកដែលពស់ចឹកនោះទេ។** ការធ្វើចលនាកាន់តែច្រើន ពិសនឹងជ្រាបចូលក្នុងរាងកាយកាន់តែលឿន។ ប្រសិនបើពស់ចឹកនៅជើង អ្នករងគ្រោះមិនត្រូវដើរឡើយ។ **បញ្ជូនគេទៅរកជំនួយពីគ្រូពេទ្យជាបន្ទាន់។**

២. ដោះគ្រឿងអលង្ការចេញ ពីព្រោះការហើមអាចរាលដាលយ៉ាងឆាប់រហ័ស។

៣. រុំមុខរបួសដោយបង់យឺត ឬក្រណាត់ស្អាត ដើម្បីពន្យឺតការរាលដាលនៃជាតិពិស។ រក្សាដៃនិងជើងឲ្យស្ងៀម ហើយរុំបង់ឲ្យតឹង ប៉ុន្តែកុំឲ្យតឹងរហូតដល់នាំឲ្យបាត់ ជីពចរនៅកដៃនិងផ្នែកខាងលើនៃប្រអប់ជើង។ បើអ្នកចាប់ជីពចរមិនបានសូមបន្ធូរបង់រុំបន្តិច។





៤. រុំប្រអប់ដៃ ឬប្រអប់ជើង រហូតដល់ដៃឬជើងទាំងមូល។ ត្រូវប្រាកដថា អ្នកនៅអាចចាប់ជីពចរបាន។



៥. បន្ទាប់មក ដាក់បន្ទះឈើអបដើម្បីការពារកុំឲ្យអវៈយវៈមានចលនា។

៦. សែងអ្នកត្រូវរបួស ទៅកាន់មណ្ឌលសុខភាពដែលនៅជិតបំផុត ដោយប្រើស្នែង បើមាន។ ប្រសិនបើអាច យកពស់នោះទៅជាមួយផង ព្រោះពស់ផ្សេងៗគ្នាអាចត្រូវប្រើថ្នាំប្រឆាំងជាតិពិសខុសៗគ្នាដែរ(អង់ទីតុកស៊ីន ទំ.៣៨៨)។ ប្រសិនបើត្រូវចាក់ថ្នាំប្រឆាំងជាតិពិសមែន ទុកបង់រុំនៅដដែលរហូតដល់បានចាក់ថ្នាំនេះរួចរាល់ និង បានអនុវត្តវិធានការប្រុងប្រយ័ត្នគ្រប់បែបយ៉ាង ចំពោះស្ទុករអាល់ឡែស៊ី( ទំ.៧០ )។ ឲ្យថ្នាំអង់ទីតុកស៊ីនតែតាំណួសផង ( ទំ.៣៨៩ )។ ប្រសិនបើគ្មានថ្នាំប្រឆាំងជាតិពិសទេ ត្រូវស្រាយបង់រុំចេញ។

**ត្រូវមានថ្នាំប្រឆាំងជាតិពិសរបស់ពស់ដែលមាននៅក្នុងតំបន់របស់អ្នក ជាស្រេច ហើយត្រូវដឹងពីរបៀបប្រើប្រាស់វា មុនពេលមាននរណាម្នាក់ត្រូវបានពស់ចឹក។**

ពស់ពិសចឹក មានគ្រោះថ្នាក់ណាស់។ ត្រូវបញ្ជូនទៅរកគ្រូពេទ្យ ប៉ុន្តែត្រូវធ្វើតាមការពន្យល់ខាងលើភ្លាមៗ។ ការព្យាបាលពស់ចឹកតាមក្បួនបុរាណ ជួយបានតិចតួចណាស់ បើវាអាចជួយ។ ការព្យាបាលខ្លះអាចបណ្ដាលឲ្យមានការបង្ករោគ ឬអាចធ្វើឲ្យឥទ្ធិពលរបស់ពិសកាន់តែធ្ងន់ធ្ងរឡើង។

**ការដែលមិនត្រូវធ្វើ ៖**

- មិនត្រូវកាត់ស្បែកឬសាច់នៅជុំវិញមុខរបួសចឹក
- មិនត្រូវចងយ៉ាងតឹងនៅជុំវិញមុខរបួស ឬដងខ្លួនរបស់អ្នករងគ្រោះ
- មិនត្រូវដាក់ទឹកកកនៅលើ ឬនៅជុំវិញមុខរបួស
- មិនត្រូវដាក់ចរន្តអគ្គីសនីឲ្យឆក់អ្នករងគ្រោះ
- មិនត្រូវព្យាយាមបឺតយកឈាម ឬពិសចេញពីមុខរបួស។
- មិនត្រូវផឹកស្រាបន្ទាប់ពីត្រូវបានពស់ចឹក។ វាធ្វើឲ្យមានគ្រោះថ្នាក់កាន់តែធ្ងន់ធ្ងរ។

## ខ្យាដំរីទិច



ខ្យាដំរីខ្លះមានពិសជាងខ្យាដំរីខ្លះទៀត។ ចំពោះមនុស្សចាស់ ខ្យាដំរីទិច កម្រមានគ្រោះថ្នាក់ណាស់។ លេបថ្នាំអាស្ពីរីន ឬប៉ារ៉ាសេតាមុល ហើយបើអាចរកបាន ដាក់ទឹកកកស្អំលើកន្លែងទិច ដើម្បីជួយបំបាត់ការឈឺចាប់។ ចំពោះការស្ពឹក និងឈឺចាប់ដែលជួនកាលមានរហូតដល់រាប់អាទិត្យ ឬរាប់ខែ ការស្អំ ទឹកក្តៅអាចជួយបាន(ទំ.១៩៣)។

ចំពោះកុមារអាយុតិចជាង៥ឆ្នាំ ខ្យាដំរីទិចអាចមានគ្រោះថ្នាក់ជាពិសេស បើវាទិចនៅក្បាលឬខ្លួន។ នៅប្រទេសខ្លះ មានថ្នាំប្រឆាំងពិសខ្យាដំរី(ទំ.៣៨៨)។ ជាការប្រសើរ ត្រូវចាក់ថ្នាំឲ្យកុមារក្នុងអំឡុងពេល២ម៉ោងបន្ទាប់ពីខ្យាដំរីទិចវា។ ឲ្យអាស្ពីរីន ឬអាសេតាមីណូហ្វែន (Paracetamol) សម្រាប់បំបាត់ការឈឺចាប់។ បើកុមារឈប់ដកដង្ហើម ផ្លុំខ្យល់តាមមាត់(មើលទំ.៨០)។ ឲ្យថ្នាំអង់ទីតុកស៊ីនតេតាណូសផង(មើលទំ.៣៨៩)។

បើកុមារដែលរងគ្រោះនោះតូចពេក ឬត្រូវបានទិចចំផ្នែកសំខាន់នៃដងខ្លួន ឬបើអ្នកដឹងថាខ្យាដំរីនោះជាប្រភេទខ្យាដំរីដែលមានគ្រោះថ្នាក់ ស្វែងរកជំនួយពីគ្រូពេទ្យជាបន្ទាន់។

## ពីងពាងខាំ

ភាគច្រើននៃការខាំរបស់ពីងពាង តែងតែធ្វើឲ្យមានការឈឺចាប់យ៉ាងខ្លាំង ប៉ុន្តែគ្មានគ្រោះថ្នាក់ទេ។



ឲ្យថ្នាំអាសេតាមីណូហ្វែន ឬអាស្ពីរីន ហើយស្វែងរកជំនួយពីគ្រូពេទ្យ។ ថ្នាំដែលសំខាន់បំផុត គឺគ្មាននៅតាមភូមិទេ។ (ការចាក់ថ្នាំកាល់ស្យូមគ្លុយកូណាត ១០% ចំនួន១០មល តាមសរសៃវ៉ែន **យឺតៗ** ក្នុងរយៈពេល ១០នាទី ជួយកាត់បន្ថយការចុករឹងសាច់ដុំ។ ជាមួយគ្នានេះ ការឲ្យថ្នាំឌីយ៉ាសេប៉ាម(ទំ.៣៩០) ក៏អាចជួយជួយទៀតដែរ។ បើមានរោគសញ្ញាស្ពុក ព្យាបាលស្ពុកអាល់ឡែស៊ី(ទំ.៧០)។ ចំពោះកុមារអាចត្រូវការការចាក់ថ្នាំក័រទីសូន(cortisone)។) ឲ្យថ្នាំអង់ទីតុកស៊ីនតេតាណូសផង(មើលទំ.៣៨៩)។ មានថ្នាំប្រឆាំងពិសនេះ ប៉ុន្តែវាពិបាករកណាស់។